ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សំភារៈ

៤១

# ទស្សនាវដ្តី គ្រូបង្រៀន



ព្រះរាជពិធីបូជាព្រះបរមសពព្រះបរមរតនកោដ្ឋព្រះករុណាព្រះបាទ នរោត្តម សីហនុ
ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៣

ឆ្នាំ២០១៣

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **រាជកិច្ច** | |
| ២ | ច្បាប់ស្តីពីការអប់រំ | ២ |
| | **វប្បធម៌ទូទៅ** | |
| ៣ | សកម្មភាពព្រះពុទ្ធសាសនាកាត់បន្ថយភាពក្រីក្រ (តចប់) | ៥ |
| ៤ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៧ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៥ | តើអ្វីខ្លះជួយអនុគ្រោះដល់ការអភិវឌ្ឍរបស់កុមារ (តចប់) | ១០ |
| ៦ | ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈជំទង់ | ១២ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៧ | ការបង្រៀនវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា(ត) | ១៥ |
| ៨ | មូលភេទ អ-អិ (តចប់) | ១៨ |
| ៩ | គណិតវិទ្យាៈ ការដោះស្រាយចំណោទ (ត) | ២០ |
| ១០ | ឪពុកម្តាយសិស្ស និងគ្រូបង្រៀនត្រូវប្រស័យទាក់ទងគ្នា | ២៣ |
| ១១ | មូលដ្ឋាននៃការអប់រំ | ២៥ |
| | **កំណាព្យ និងកំសាន្ត** | |
| ១២ | ប្រាសាទព្រះវិហារខ្មែរជាបេតិកភ័ណ្ឌពិភពលោក | ២៧ |
| ១៣ | ម្តាយ និងកូនរួមគ្នាអភិវឌ្ឍសង្គម | ២៨ |
| ១៤ | អនិច្ចាផ្កាសាកល | ២៩ |
| ១៥ | ក្រុងថ្មីនៃកម្ពុជា | ៣០ |
| ១៦ | ត្រូវចៀសវាងពីគ្រឿងញៀន | ៣២ |
| | **វេទិកាស្ត្រី** | |
| ១៧ | ប្រវត្តិឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ | ៣៣ |
| ១៨ | វេទិកាស្ត្រីៈ គោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ (ត) | ៣៥ |
| | **ព័ត៌មាន** | |
| ១៩ | តើលោកគ្រូ អ្នកគ្រូដឹងឬទេ? | ៣៧ |
| ២០ | ចំនួនឃុំ/សង្កាត់ មិនមានសាលាមធ្យមសិក្សា តាមខេត្ត-រាជធានី ២០០៧-២០១១ | ៣៨ |
| ២១ | ស្ថិតិសមាជិក តាមរាជធានី-ខេត្ត និងគណៈកម្មាធិការកណ្តាល ប្រចាំឆ្នាំ២០១២ | ៣៩ |
| ២២ | ស្ថិតិសពខែកញ្ញា-ធ្នូ ឆ្នាំ២០១២ | ៤០ |



**គណៈកម្មការរៀបរៀង និងនិពន្ធ**

- លោក ជ័យ សយ្យនា
- លោក ថោង បូរ៉ាន់
- លោកស្រី គួយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈាងលី
- លោក គៅ ជឿន
- លោក ស្វាយ និត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ថាច់ ធីសា៉រ៉ែន
- លោកស្រី ប៊ុន សា៉រ៉ែន
- សមាជិក-សមាជិកាស.ប.ស.ខ

**គណៈកម្មការត្រួតពិនិត្យ**

- លោក យស់ អ៊ាង
- លោកស្រី ធន់ សារ៉ឹម
- លោក អ៊ិន ថេរ
- លោក រ័ត្ន ហួត
- លោក សួង សារុណ
- លោក ស៊ុង ចាន់ថន
- លោក ស៊ិន ស៊ឹម

**ការិយាល័យ**

អ្នកស្រី ម៉ៃ សូនី

**ក្របខាងក្រៅ**

- **ពីមុខ:** ព្រះរាជពិធីបូជាព្រះបរមសពព្រះបរមរតនកោដិព្រះករុណាព្រះបាទ នរោត្តម សីហនុ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣
- **ពីក្រោយ:** "រូបពីរ" នៅសួនច្បារមុខស្ថានទូតបារាំង។ ឥឡូវមានសល់បំណែកមួយចំនួននៅសារមន្ទីរជាតិ។



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

| | | | |
|---|---|---|---|
| **ភ្នំពេញ** | : ០៨៩ ៦៨៨ ០៨១ | **កំពត** | : ០១២ ៨៥៦ ៧២២, |
| **ព្រះសីហនុ** | : ០១២ ៦៥៩ ៥៦០ | **កែប** | : ០៩៧ ៨៧២១ ៨៨០ |
| **សៀមរាប** | : ០១២ ៦៧៥ ៦៤០ | **តាកែវ** | : ០៩៧ ៩៧៦១ ៥៨៨ |
| **កំពង់ចាម** | : ០១១ ៧៤២ ២២៤ | **រតនគិរី** | : ០១២ ៦១៩ ៥២៨ |
| **ស្វាយរៀង** | : ០៩៧ ២៦៥៥ ៩៨៧ | **ព្រះវិហារ** | : ០១២ ២១៨ ២៨១ |

# វិចារណកថា

តាមន័យរបស់ពាក្យ ពលរដ្ឋ ពាក្យនេះសំដៅដល់ប្រជាជនទាំងប្រុសទាំងស្រី ក្នុងឋានៈជាសមាជិក សមាជិកានៃប្រទេសមួយដែលមានករណីយកិច្ច និងសិទ្ធិស៊ីវិល ក៏ដូចជាសិទ្ធិនយោបាយ ដើម្បីបំពេញតាមនាទី ភារកិច្ចរៀងៗខ្លួន។

តើករណីយកិច្ច និងសិទ្ធិក្នុងបរិបទសព្វថ្ងៃនៃព្រះរាជាណាចក្រកម្ពុជាមានខ្លឹមសារយ៉ាងណា? ករណីយកិច្ចគឺជាសកម្មភាពរបស់ពលរដ្ឋ ដែលតម្រូវឱ្យធ្វើដោយច្បាប់ និងសីលធម៌។

ឧទាហរណ៍ៈ ពលរដ្ឋមានកាតព្វកិច្ចត្រូវបង់ពន្ធអាករជូនរដ្ឋ ឬត្រូវចូលបម្រើក្នុងទ័ព តាមច្បាប់កំណត់។

ឧទាហរណ៍ៈ ពលរដ្ឋមានកាតព្វកិច្ចត្រូវជួយសង្គ្រោះមនុស្សដែលជួបគ្រោះថ្នាក់តាមសីលធម៌របស់សង្គម។

ទន្ទឹមនឹងករណីយកិច្ច ពលរដ្ឋក៏មានសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយដែរ។ សិទ្ធិនេះមានន័យថា ជាគោលការណ៍ទូទៅសម្រាប់គ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល និងសម្រាប់ចងក្រងរៀបចំជាវិធានគតិយុត្តក្នុងក្របខ័ណ្ឌនៃច្បាប់រដ្ឋប្បវេណី។

ឧទាហរណ៍ៈ សិទ្ធិស៊ីវិលរបស់ពលរដ្ឋគឺសិទ្ធិដែលគេត្រូវទទួលបាននូវលិខិតបញ្ជាក់អត្រានុកូលដ្ឋាន។

ឧទាហរណ៍ៈ សិទ្ធិនយោបាយរបស់ពលរដ្ឋ គឺសិទ្ធិបោះឆ្នោត ឈរឈ្មោះបោះឆ្នោត។ល។

អ្វីដែលបានបរិយាយខាងលើ ទើបគេមានលក្ខណៈជាពលរដ្ឋពេញលេញ។ ជាក់ស្តែង សម្រាប់បរិការណ៍កម្ពុជា ថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ គឺជាថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ដែលពលរដ្ឋគ្រប់ៗរូបជាអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានលិខិតបញ្ជាក់អត្តសញ្ញាណត្រូវអញ្ជើញទៅបោះឆ្នោតតាមកាលបរិច្ឆេទខាងលើ។ ការសម្រេចចិត្តក្នុងការជ្រើសរើសគណបក្សនយោបាយណាមួយនាពេលបោះឆ្នោត ជាសិទ្ធិស្វ័យសម្រេចរបស់អ្នកបោះឆ្នោត។ ក៏ប៉ុន្តែអ្នកបោះឆ្នោតគប្បីពិចារណាឱ្យបានល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយមុននឹងបោះឆ្នោត ព្រោះការសម្រេចចិត្តនេះមានសារៈសំខាន់ណាស់។ បើយើងសម្រេចចិត្តបានត្រឹមត្រូវ ប្រទេសជាតិនឹងមានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ។ ផ្ទុយទៅវិញ បើយើងសម្រេចចិត្តខុស ប្រទេសជាតិនឹងជួបប្រទះនូវវិបល្លាសទៅលើសមិទ្ធផលបច្ចុប្បន្នជាមិនខាន។

ដូចនេះ សូមពលរដ្ឋគ្រប់ៗរូបអញ្ជើញទៅបោះឆ្នោតនៅថ្ងៃអាទិត្យ ទី២៨ ខែកក្កដា ឆ្នាំ២០១៣ ឱ្យបានគ្រប់ៗគ្នា និងឱ្យបានត្រឹមត្រូវ៕

**គណៈកម្មាធិការកណ្តាល**

# ច្បាប់ស្តីពីការអប់រំ

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវទទួលខុសត្រូវរៀបចំលិខិតបទដ្ឋានសម្រាប់ការប្រឡងនេះ ។

## ជំពូកទី ៦
## គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ

**មាត្រា ២៧.- ការកំណត់គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកសាងផែនការគោលសម្រាប់អភិវឌ្ឍវិស័យអប់រំ អនុលោមតាមគោលនយោបាយអប់រំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងការត្រួតពិនិត្យកែសម្រួលគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ ស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៨.- វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំ**

រដ្ឋត្រូវលើកកម្ពស់ និងគាំទ្រដល់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ ការច្នៃប្រឌិតនិងការផលិតដែលមានលក្ខណវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងស្របតាមសាកលភាវូបនីយកម្ម ដើម្បីលើកស្ទួយសមត្ថភាពធនធានមនុស្ស និងជំរុញការអភិវឌ្ឍប្រទេសជាតិ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់គោលការណ៍ស្តីពីវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំគ្រប់កម្រិតសិក្សានៃប្រព័ន្ធអប់រំកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៩.- ភាពជាដៃគូសម្រាប់ការអប់រំ**

រដ្ឋត្រូវបើកទូលាយឱ្យមានការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់មានជាអាទិ៍ ផ្នែកសាធារណៈ ផ្នែកឯកជន អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ នៅក្នុងដំណើរការនៃការអភិវឌ្ឍការតាក់តែង ការតាមដានវាយតម្លៃលើការអនុវត្ត ការលើកសំណើឱ្យពិនិត្យឡើងវិញ និងសំណើកែលម្អ គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រជាតិអប់រំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ៗ-

រដ្ឋលើកទឹកចិត្ត និងគាំទ្រដល់ស្ថាប័នឯកជន ដើម្បីបង្កើតភាពជាដៃគូក្នុងការផ្តល់សេវាអប់រំគ្រប់ប្រភេទ និងគ្រប់កម្រិត ។

**មាត្រា ៣០.- អាហារូបករណ៍ និងឧបត្ថម្ភធន**

រដ្ឋត្រូវកំណត់គោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ ឧបត្ថម្ភធន និងឥណទានសម្រាប់អ្នកសិក្សា ។

រដ្ឋលើកទឹកចិត្តចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គលដែលផ្តល់អាហារូបករណ៍ ឬឧបត្ថម្ភធនសម្រាប់អ្នកសិក្សា ។

## ជំពូកទី ៧
## សិទ្ធិ និងករណីយកិច្ចអប់រំ

**មាត្រា ៣១.- សិទ្ធិទទួលការអប់រំ**

ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច ៩ (ប្រាំបួន) ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងវិធានការជាជំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣២.- សិទ្ធិចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១ (មួយ) នៃកម្មវិធីអប់រំចំណេះទូទៅ**

ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី ១ (មួយ) នៃកម្មវិធីអប់រំចំណេះទូទៅក្នុងប្រព័ន្ធត្រូវបានកំណត់ចំពោះកុមារ ដែលមានអាយុចាប់ពី ៦ (ប្រាំមួយ) ឆ្នាំ ឬ យ៉ាងទាបបំផុត ៧០ (ចិតសិប) ខែឡើងទៅ នៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន ។

**មាត្រា ៣៣.- សិទ្ធិ សេរីភាពខាងជំនឿសាសនានៅក្នុងការអប់រំ**

រដ្ឋគោរពសិទ្ធិ សេរីភាពខាងជំនឿសាសនា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ។ គ្រប់ការបង្ខំឱ្យអ្នកសិក្សា និងអ្នកពាក់ព័ន្ធការអប់រំឱ្យចូលរួមក្នុងសកម្ម-

LE MINISTRE DU PALAIS ROYAL

ភាពសាសនា និង/ឬ ការប្រតិបត្តិសាសនាណាមួយដែលជាផ្នែកនៃការអប់រំ ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី ត្រូវហាមឃាត់ ។

ការសិក្សាអំពីសាសនានៅក្នុងកម្មវិធីសិក្សា ត្រូវបានអនុញ្ញាតសម្រាប់តែការយល់ដឹងទូទៅប៉ុណ្ណោះ ។

**មាត្រា ៣៤.– សកម្មភាពនយោបាយក្នុងស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា**

ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវគោរពគោលការណ៍អព្យាក្រឹតភាព ។

ការធ្វើសកម្មភាពនយោបាយ និង/ឬ ការឃោសនានយោបាយឱ្យគណបក្សនយោបាយណាមួយក្នុងស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវហាមឃាត់ ។

**មាត្រា ៣៥.– សិទ្ធិ និងករណីយកិច្ចរបស់អ្នកសិក្សា**

សិទ្ធិរបស់អ្នកសិក្សាទាក់ទងនឹងការអប់រំមានដូចតទៅ :

- សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី
- សិទ្ធិមានសេរីភាពខាងការសិក្សា
- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព
- សិទ្ធិប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬ ក្លឹបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ
- សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្តីពីការអប់រំ
- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដារអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬ តាមរយៈតំណាងរបស់ខ្លួន
- សិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សជាពិសេសសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬ ការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ។

ករណីយកិច្ចរបស់អ្នកសិក្សាមានដូចតទៅ :

- គោរពបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រ ដោយអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL




# សកម្មភាពពុទ្ធសាសនាកាត់បន្ថយភាពក្រីក្រ (តចប់)

## ៤. ពិធីបុណ្យក្នុងព្រះពុទ្ធសាសនា

ពុទ្ធសាសនិកជន ប្រជាពលរដ្ឋខ្មែរស្ទើរតែទាំងអស់ តែងមានជំនឿលើបុណ្យកុសលថា នាំមកនូវសេចក្ដីសុខ ចម្រើន សិរីសួស្ដីជ័យមង្គល។ ដូច្នេះហើយទើបពួកគេមានសទ្ធាលះបង់នូវទេយ្យវត្ថុផ្សេងៗ ជាទាន ឬកសាងវត្តអារាម កុដិ សាលាជាដើម ដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា និងធ្វើបុណ្យទានផ្សេងៗទៅតាមទំនៀមទំលាប់ប្រពៃណី។ តើពិធីបុណ្យផ្សេងៗនៅក្នុងព្រះពុទ្ធសាសនាមានផលប៉ះពាល់ដល់ជីវភាពរបស់ប្រជាពលរដ្ឋដែរឬយ៉ាងណា?

ព្រះពុទ្ធសាសនាមានជំហរមួយយ៉ាងរឹងមាំ ច្បាស់លាស់ គឺមិនបង្ខំជនណាម្នាក់ឱ្យជឿតាម ឬប្រតិបត្តិតាមដោយប្រាសចាកបញ្ញានោះឡើយ (ញាណវិប្បយុត្ត) ពោលគឺមុននឹងឱ្យលះបង់ទេយ្យវត្ថុធ្វើបុណ្យកុសល ត្រូវចេះគិតប៉ាន់ប្រមាណទៅនឹងទ្រព្យដែលខ្លួនមាន និងផលដែលខ្លួនត្រូវទទួលបានជាមុន ហើយត្រូវធ្វើដោយមញ្ញាពិចារណាត្រឹមត្រូវ (ញាណសម្បយុត្ត)។ ដូច្នេះយើងអាចនិយាយបានថា ពួកគេពិចារណាឃើញផលដែលគេត្រូវទទួលបានពីការធ្វើបុណ្យកុសលនោះជាស្រេចហើយទើបគេធ្វើ។ បើគេយល់ថាធ្វើបុណ្យច្រើននាំឱ្យគេអស់ទ្រព្យ នាំឱ្យក្រីក្រ នាំឱ្យវង្វេងទុក្ខវេទនា នោះគេពិតជាមិនអាចធ្វើទៅបានឡើយ មានតែអ្នកមិនធ្លាប់ធ្វើបុណ្យទេទើបគិតដូច្នោះ។ តាមពិតពាក្យ ធ្វើបុណ្យ មានន័យថា ការធ្វើសេចក្ដីអនុគ្រោះ ការជួយស្រោចស្រង់ ការផ្ដល់នូវសេចក្ដីសុខដល់អ្នកដទៃ ការជួយសង្គ្រោះគ្នា។ល។ ហើយជាគុណធម៌ដែលមនុស្សគ្រប់រូបត្រូវតែមាន ត្រូវតែធ្វើ។

ពិធីបុណ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានច្រើនប្រភេទ គឺពិធីបុណ្យជាតិ ពិធីបុណ្យប្រពៃណី ពិធីបុណ្យសាសនា និងពិធីបុណ្យតាមទំនៀមទំលាប់ផ្សេងៗ។ល។ ចំពោះពិធីបុណ្យនីមួយៗ[១] តើមានសារប្រយោជន៍អ្វីខ្លះសម្រាប់ជួយដល់សង្គម ឬប្រជាពលរដ្ឋខ្មែរយើង?

ប្រសិនបើយើងធ្វើការពិចារណាទៅលើផល ដែលបានមកពីការចំណាយទ្រព្យធនរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើបុណ្យកុសលផ្សេងៗសម្រាប់ជាការជួយដល់សង្គម គឺមានច្រើនណាស់ដូចជា៖

- ការប្រមូលថវិកា ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជាប្រយោជន៍សាធារណៈមានស្ពាន ថ្នល់ ស្រះទឹក អណ្ដូងទឹក ប្រព័ន្ធធារាសាស្ត្រ សាលាសំណាក់ផ្សេងៗ...។
- កសាងវត្តអារាមដែលជាសម្បត្តិវប្បធម៌ជាតិ
- ប្រមូលថវិកាជួយជនរងគ្រោះផ្សេងៗមានគ្រោះទឹកជំនន់ ភ្លើងឆេះផ្ទះ...
- អភិរក្សវប្បធម៌ អរិយធម៌ ទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ជាតិ
- ជួយសង្គ្រោះគ្នា ស្រោចស្រង់គ្នាពេលមានធុរៈធ្ងន់ធ្ងរ ជួយគ្នាក្នុងគ្រាក្រ

(១) សូមមើល ខ្លូត ធីតា ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរភាគ២ ព.ស២៥៤៧ គ.ស២០០៤

- អប់រំគុណធម៌ សីលធម៌សង្គម។ល។

ពិធីបុណ្យក្នុងព្រះពុទ្ធសាសនាមានច្រើន តែមិនបានធ្វើឱ្យប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋឡើយ ផ្ទុយទៅវិញមានតែនាំមកនូវផលប្រយោជន៍ជាច្រើនជួយដល់សង្គមជាតិថែមទៀតផង។

បច្ចុប្បន្នជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានលក្ខណៈល្អប្រសើរបានមួយកម្រិត បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ដោយសារការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល ពិសេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍន៍ជនបទ។ ដោយសារប្រទេសកម្ពុជាជាប្រទេសមួយដែលប្រជាពលរដ្ឋមានជំនឿជឿជាក់លើបុណ្យកុសល ឬព្រះពុទ្ធសាសនាយ៉ាងស៊ប់សួន ដូច្នេះហើយចំពោះការអភិវឌ្ឍប្រទេសជាតិ ពិតជាមិនអាចផ្តាច់ខ្លួនចេញពីព្រះពុទ្ធសាសនាបានឡើយ មិនត្រឹមតែប៉ុណ្ណោះថែមទាំងត្រូវយកព្រះពុទ្ធសាសនាជាជំហរក្នុងការដឹកនាំប្រទេសជាតិ ក៏ដូចជាប្រជាពលរដ្ឋផងដែរ ព្រោះនៅប្រទេសកម្ពុជាយើង ពុទ្ធចក្រ និងអាណាចក្រ កង់ទាំងពីរនេះត្រូវវិលដើរទន្ទឹមគ្នា មិនអាចខ្វះមួយណាបានឡើយ។

វត្តអារាម និងព្រះសង្ឃ មានតួនាទីដ៏សំខាន់ក្នុងសកម្មភាពអប់រំប្រជាពលរដ្ឋឱ្យពួកគេបានស្គាល់ពីហេតុផលនៃសេចក្តីចម្រើន សេចក្តីវិនាសអន្តរាយដែលជះឥទ្ធិពលដល់ខ្លួន ក្រុមគ្រួសារ និងសង្គមជាតិទាំងមូល។ អប់រំឱ្យស្គាល់ពីរបៀបរបបនៃការរស់នៅក្នុងសង្គមដែលប្រកបដោយសេចក្តីថ្លៃថ្នូរ ស្គាល់ពីរបៀបនៃការសេពគប់ ទំនាក់ទំនងការគ្រប់គ្រងក្រុមគ្រួសារ និងសង្គមជាតិជាដើម។

ក្នុងការអភិវឌ្ឍសង្គមជាតិ ព្រះពុទ្ធសាសនាបានជ្រើសយកការអភិវឌ្ឍធនធានមនុស្សជាគន្លាចម្បង និងចាំបាច់បំផុត គឺអភិវឌ្ឍទាំងកាយ វាចា និងចិត្ត ដោយហាមមិនឱ្យធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង គឺអប់រំមនុស្សឱ្យឈប់ធ្វើអំពើអាក្រក់ ថោកទាបទាំងពួងដូចជា ការបៀតបៀនកាប់សម្លាប់ ការលួចឆក់ប្លន់ កេងប្រវ័ញ្ចទ្រព្យសម្បត្តិគេ ឬទ្រព្យសម្បត្តិជាតិ ការប្រព្រឹត្តខុសក្នុងកាម។ និយាយដោយសង្ខេប គឺបញ្ឈប់អំពើរំលោភឈ្លានពានទៅលើសិទ្ធិសេរីភាពអ្នកដទៃ មានន័យថាបញ្ឈប់ការបំផ្លិចបំផ្លាញផលប្រយោជន៍ខ្លួនឯង។

អប់រំឱ្យខំបំពេញសេចក្តីល្អ គឺអប់រំឱ្យខំធ្វើអំពើល្អគ្រប់បែបយ៉ាងដូចជាការធ្វើទាន ការជួយសង្គ្រោះជីវិតគេ ការជួយឧបត្ថម្ភអ្នកទន់ខ្សោយឱ្យរួចផុតភាពអត់ឃ្លាន ភាពក្រីក្រ ការឈឺថ្កាត់ និងភាពល្ងង់ខ្លៅ ក៏ដូចជាការបំពេញនូវសង្គហធម៌ ជួយសង្គ្រោះគ្នាទៅវិញទៅមករវាងមាតាបិតា និងបុត្រធីតា រវាងគ្រូ និងសិស្សានុសិស្ស រវាងស្វាមី និងភរិយា រវាងអ្នកដឹកនាំគេ និងអ្នកដែលត្រូវគេដឹកនាំ ការរក្សាសីល៥ សីល៨ សីល១០ជាដើម និងឱ្យចេះរក្សាការពារធនធានធម្មជាតិ សម្បត្តិវប្បធម៌ជាតិ ពោលគឺឱ្យខំព្យាយាមប្រឹងប្រែងកសាងជីវិតសន្តិភាព និងវឌ្ឍនភាពជូនសង្គមជាតិ និងមនុស្សជាតិទាំងអស់លើពិភពលោក។

អប់រំសំអាតចិត្តឱ្យបរិសុទ្ធ គឺអប់រំមនុស្សឱ្យខំប្រព្រឹត្តប្រតិបត្តិ ធ្វើចិត្តឱ្យឃ្លាតឆ្ងាយចាកកិលេស គឺលោភៈ ទោសៈ មោហៈ ដែលជាឫសគល់នៃអំពើទុច្ចរិតទាំងពួង រហូតដល់កិលេស តណ្ហាទាំងឡាយរលាយអស់ពីខន្ធសន្តាន។

ទាំងអស់នេះ ជាមូលដ្ឋានគ្រឹះនៃធនធានមនុស្សដ៏សំខាន់បំផុត គឺជាការអភិវឌ្ឍទាំងកាយ វាចា ចិត្តដែលជាឫសគល់ ឬជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍទាំងពួង។ ការអប់រំបែបព្រះពុទ្ធសាសនា មានលក្ខណៈអប់រំបុគ្គលម្នាក់ៗ (អប់រំខ្លួនឯង) ឱ្យបានល្អប្រសើរជាមុន ទើបអប់រំក្រុមពួកជាក្រោយ គឺអប់រំតាំងពីថ្នាក់ទាបរហូតដល់ថ្នាក់ខ្ពស់។

យោងតាមទិដ្ឋភាពជាក់ស្តែង និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល បើយើងធ្វើការសំយោគជាមួយនឹងមាគ៌ាអភិវឌ្ឍរបស់ព្រះពុទ្ធសាសនា យើងពិតជាទទួលបាននូវសក្តានុពលទាំងប្រសិទ្ធភាព ទាំងគុណភាពក្នុងទិសដៅកាត់បន្ថយភាពក្រីក្រនេះជាក់ជាមិនខាន ក្នុងលក្ខខណ្ឌដែលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអនុវត្តព្រមៗគ្នា។ បញ្ហាទាំងអស់នេះ ទាមទារជាចាំបាច់នូវការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋទាំងសមត្ថភាព ទាំងការតស៊ូ ព្យាយាមរបស់ពួកគេដោយផ្ទាល់ផងដែរ៕

អនុបណ្ឌិត **ឡូយ សុខាន**

# ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

**ខ-តម្រូវការសម្រាប់ភាពចុះសម្រុងនឹងគ្នា**

ខុងជឺ បានរស់នៅក្នុងកំឡុងពេលមានសង្គ្រាមរាំងរៀននានានៃប្រវត្តិសាស្ត្រចិន គឺសម័យកាលមួយនៃភាពចលាចលវឹកវរ អំពើក្បត់ និងទំនាស់។ មេទ័ពដែលមានការប្រកួតប្រជែង ដោយប្រើប្រាស់ភាពឈ្លាសវៃ ចិត្តរឿចរេរ និងកម្លាំងដូចសត្វតិរច្ឆាន បានតស៊ូប្រយុទ្ធដើម្បីអំណាច។ សន្ធិសញ្ញាផ្សេងៗត្រូវបានគេបង្កើតឡើង ហើយបន្ទាប់មកមិនត្រូវបានគេយកមកអនុវត្ត។ អំពើស៊ីសំណូកសូកប៉ាន់ធ្វើឱ្យពួកគេពេញចិត្តជាខ្លាំង ការលួចធ្វើឃាត គឺជារឿងធម្មតា។ ដើម្បីឆ្លើយតបទៅនឹងសម័យកាលបែបនេះ ខុងជឺ បានបង្កើតទស្សនវិជ្ជាអប់រំ និងសីលវិទ្យា ដើម្បីស្តារសន្តិភាព និងភាពចុះសម្រុងគ្នានៅប្រទេសចិន។ ដោយជឿជាក់ថាចំណេះដឹងអាចជំនួសកម្លាំង គាត់បានបង្កើតសាលារៀនមួយដែលគាត់អាចអប់រំមន្ត្រីរដ្ឋាភិបាល នាពេលអនាគត ដើម្បីគ្រប់គ្រងប្រទេសចិនដោយយុត្តិធម៌ ភាពត្រឹមត្រូវ និងសណ្តាប់ធ្នាប់។

**គ-ទម្លាប់ និងរបៀបរបប**

សម្រាប់ខុងជឺ គោលដៅឧត្តុង្គឧត្តមរបស់ការអប់រំ គឺត្រូវអភិវឌ្ឍមនុស្សដែលមានអត្តចរិតថ្លៃថ្នូរដែលតាមការសិក្សាដោយយកចិត្តទុកដាក់ និងជាបន្តបន្ទាប់ទទួលបានចំណេះដឹងចាំបាច់ ដើម្បីអនុវត្តតាមរបៀបមធ្យោបាយមួយដែលនាំទៅដល់ចិត្តមេត្តា ជាជាងហិង្សា។ តាមការស្វែងរកការកាត់បន្ថយការព្រួយបារម្ភដែលបណ្តាលឱ្យមានការផ្លាស់ប្តូរភ្លាមនោះ ខុងជឺ បានរៀបចំចាត់ចែងប្រព័ន្ធអប់រំ និងសីលវិទ្យានៅជុំវិញការសិក្សាពីរបៀបសង្កេតទម្លាប់ និងរបៀបរបបគ្រប់គ្រងទំនាក់ទំនងមនុស្សតាមឋានានុក្រមសង្គម។ ឧត្តមគតិនៃទំនាក់ទំនងតាមឋានានុក្រមអាចត្រូវបានពណ៌នាថា ជាកាំជណ្តើរសីលវិទ្យាដែលមនុស្សកំពុងតែឈរ នៅលើកាំនីមួយៗត្រូវបានភ្ជាប់ទៅនឹងមនុស្សដែលកំពុងតែឈរនៅខាងលើ និងខាងក្រោម។ មនុស្សរាល់គ្នាតាមឋានានុក្រមគួរតែដឹងយ៉ាងច្បាស់លាស់នូវឋានៈរបស់ខ្លួន និងការទទួលខុសត្រូវ ហើយនិងរបៀបដ៏សមរម្យនៃការប្រព្រឹត្តចំពោះមនុស្សផ្សេងទៀត។

**ឃ-ឋានានុក្រម**

ក្នុងនាមជាគ្រូបង្រៀនម្នាក់ តើអ្នកនឹងជួយសិស្សរបស់អ្នកដើម្បីឱ្យអភិវឌ្ឍទំនាក់ទំនង និងតម្លៃរបស់មនុស្សជាវិជ្ជមានយ៉ាងដូចម្តេច? តើតម្លៃទាំងនេះនឹងឆ្លុះបញ្ចាំងស្តង់ដារប្រពៃណី ឬវានឹងមិនមានដែនកំណត់? បញ្ញត្តិនៃទំនាក់ទំនងសីលវិទ្យាតាមឋានានុក្រម មានការអនុវត្តជាសំខាន់សម្រាប់ការអប់រំ ជាពិសេសការបង្កើតអត្តចរិត។ តាមខុងជឺ បញ្ញត្តិនៃទំនាក់ទំនងតាមឋានានុក្រមដែលបុគ្គលមួយចំនួនមានភាពខ្ពង់ខ្ពស់ ហើយអ្នកផ្សេងទៀតមានភាពតូចតាចខុសគ្នាយ៉ាងខ្លាំងពីគំនិតសាមញ្ញរបស់យើងសព្វថ្ងៃដែលទំនាក់ទំនងមនុស្សផ្អែកលើសមភាព។

តាមលក្ខខណ្ឌសមភាព បុគ្គលដែលចូលរួមក្នុងទំនាក់ទំនងមួយ កំណត់ជាបន្តបន្ទាប់នូវទំនាក់ទំនង និងបង្កើតការបើកចំហថ្មីៗចំពោះគ្នាទៅវិញទៅមក ហើយជាញឹកញាប់បង្កើត ឬបង្កើតឡើងវិញនូវដែនកំណត់ទាំងឡាយ។ ការអប់រំអត្តចរិតក្នុងស្ថានភាពនៃសមភាព នាំទៅដល់បញ្ញត្តិសីលវិទ្យា ដែលយើងគួរប្រព្រឹត្តដល់បុគ្គលម្នាក់ៗថា មានភាពស្មើៗគ្នា ហើយយើងគួរតែគោរព និងវាយតម្លៃនូវភាពខុសគ្នារបស់គេពីយើង។

ផ្ទុយទៅវិញ សីលវិទ្យាខុងជឺ បង្កើតគំរូជាក់លាក់នៃអាកប្បកិរិយា ជាជាងភាពបត់បែន ឬទន់ភ្លន់។ មនុស្សត្រូវបានអនុញ្ញាតឱ្យមានកម្រិតគោរពផ្សេងៗគ្នា ដោយផ្អែកទៅលើតំណែង ឬឋានៈ និងសមិទ្ធផល។ ការអប់រំអត្តចរិតមានន័យថា រៀនពីតួនាទីនៅក្នុងបណ្តាញទំនាក់ទំនងដែលបង្កើតបានសហគមន៍ និងដើម្បីបំពេញអាកប្បកិរិយាតាមតួនាទីទៅតាមបញ្ញត្តិ ដែលធានាដល់ភាពចុះសម្រុងគ្នានៅក្នុងសង្គម។

ការផ្លាស់ប្តូរ ភាពថ្មីប្លែកៗ នវានុវត្តន៍ អាចនាំដល់ក្តីមិនរំពឹងទុកមុន ហើយការផ្លាស់ប្តូរដោយមិនរំពឹងទុកមុន គឺជាបញ្ហាសង្គមមួយនៅក្នុងពេលនេះដែល ខុងជឺ បានផ្ដែកប្រព័ន្ធសីលវិទ្យាទៅតាមប្រពៃណី។ ការប្រតិបត្តិដ៏ពិតប្រាកដមួយ ឬកិរិយាដែលរួមចំណែកដល់ការរក្សាសន្តិភាព សន្តិសុខ និងភាពរៃងាប់ចិត្តក្នុងអតីតកាលនៃតម្លៃដែលត្រូវបានស្រោបក្នុងរបៀបតាមទម្លាប់នៃការប្រព្រឹត្ត ត្រូវបានផ្ទេរ និងប្រតិបត្តិដោយមនុស្សនាពេលបច្ចុប្បន្ន។ តាមខុងជឺ មនុស្សម្នាក់ដែលមានតម្លៃជាគ្រូ ត្រូវចេះដឹងពីអ្វីដែលថ្មី តាមការរក្សាចំណេះដឹងថ្មីៗក្នុងចិត្ត និងអ្វីៗដែលគាត់បានចេះដឹងរួចមកហើយ។

**ឃ-ការគោរពចំពោះគ្រូ**

នៅប្រទេសចិន ទំនាក់ទំនងរវាងគ្រូ និងសិស្សដូចទំនាក់ទំនងផ្សេងៗទៀតដែរ គឺមានភាពល្បីល្បាញ និងត្រូវមានភាព ជាក់លាក់។សិស្សត្រូវគោរពគ្រូរបស់គេជាខ្លាំង និងខ្ពង់ខ្ពស់។ សិស្សផ្ទាល់របស់ខុងជឺ បានហៅគាត់ថា លោកម្ចាស់។ ការគោរពចំពោះការអប់រំ ការសិក្សា និងគ្រូ បានក្លាយជាលក្ខណៈពិសេសដ៏សំខាន់នៃការអប់រំក្នុងប្រទេសចិន និងអាស៊ីអាគ្នេយ៍ ដែល ខុងជឺ បានក្លាយជាបញ្ញវន្តចម្បង និងជាកម្លាំងអប់រំ។

## ២-២ ការរួមចំណែករបស់ចិន ចំពោះការអប់រំពិភពលោក

**សារៈសំខាន់នៃការប្រលង**

កេរដំណែលអប់រំដ៏សំខាន់ពីចិនបុរាណ គឺប្រព័ន្ធការប្រឡងថ្នាក់ជាតិ។ គរវិទូចិន បានអភិវឌ្ឍការប្រឡងបែបសរសេរតាមការយល់ដឹង ដើម្បីវាយតម្លៃសមត្ថភាពសិក្សារបស់សិស្ស។ សិស្សបានត្រៀមរៀបចំដើម្បីប្រឡង តាមការសិក្សាអក្សរសិល្ប៍ចិនបុរាណ និងអត្ថបទខុងជឺ ជាមួយគ្រូនៅសាលាតាមព្រះវិហារ ឬព្រះបរមរាជវាំង។ ការប្រឡងសង្កត់ធ្ងន់ទៅលើការចងចាំ ដោយទន្ទេញព័ត៌មានជាជាងដោះស្រាយបញ្ហាជាក់ស្តែង។ ដំណើរការប្រឡងដូចជាសង្គមបានដំណើរការតាមឋានានុក្រម និងតាមការជ្រើសរើស។ សិស្សត្រូវតែប្រឡងជាប់នូវលំដាប់នៃការប្រឡងដ៏លំបាកតាមលំដាប់កើនឡើង។ ប្រសិនបើគេប្រឡងធ្លាក់ គេនឹងត្រូវបណ្តេញចេញពីដំណើរការនោះ។ នៅក្នុងសម័យកាលនោះ មានតែអ្នកប្រឡងដល់ទីបញ្ចប់តិចតួចតែប៉ុណ្ណោះ អាចទទួលតំណែងសេវាកម្មស៊ីវិលជាន់ខ្ពស់បំផុតរបស់ចក្រភពចិន។ ប្រព័ន្ធអប់រំ និងការប្រឡងត្រូវបានរក្សាទុកឱ្យតែមនុស្សប្រុសវណ្ណៈខ្ពស់ប៉ុណ្ណោះ។ ស្ត្រីមិនអាចទទួលតំណែងក្នុងរដ្ឋាភិបាល ហើយក៏មិនមានសិទ្ធិចូលរៀនផងដែរ។

## ៣-ការអប់រំតាមអរិយធម៌ឥណ្ឌាបុរាណ

**ក-សមតាវប្បធម៌**

ដូចជាប្រទេសចិន ឥណ្ឌា មានអរិយធម៌បុរាណមួយ។ អរិយធម៌ទាំងឡាយដែលមាននៅតាមជ្រលងភ្នំ ទន្លេបានលូតលាស់បានល្អ នៅតាមច្រាំងទន្លេឥណ្ឌុស (indus) របស់ឥណ្ឌានៅ Mohenjo-daro and Harrapa ពីឆ្នាំ ៣០០០ ទៅដល់១៥០០មុនគ.ស.។ ប្រវត្តិអប់រំរបស់ឥណ្ឌាបានលាតត្រដាងនូវគំរូនៃការឈ្លានពានជាខ្ទៅដោយអ្នកលុកលុយឈ្លានពានដែលបន្ទាប់មកដោយការប៉ះទង្គិចខាងវប្បធម៌ ជាមួយជនជាតិដើម ហើយបន្ទាប់មកគឺការស្តារសមតាវប្បធម៌សង្គម។ នៅក្នុងសមតាវប្បធម៌នេះ អ្នកឈ្លានពានត្រូវបានគេស្រូបទាញយកទៅជាវប្បធម៌ឥណ្ឌាដែលនៅពេលជាមួយគ្នានោះ ជនជាតិដើម បានខ្ចីគំនិតពីអ្នកឈ្លានពានលុកលុយមួយចំនួន។

**ខ-ប្រវត្តិសង្ខេប**

នៅក្នុងចំណោមអ្នកលុកលុយជំនាន់ដើមរបស់ឥណ្ឌា គឺពួកអារ្យ៉ែន ជាបុព្វបុរសនៃអម្បូរជនភាគច្រើន ដែលនិយាយភាសាហិណ្ឌីរបស់ឥណ្ឌាដែលបានចូលលុកលុយឥណ្ឌាក្នុង១៥០០ឆ្នាំមុនគ.ស. ហើយបានបង្ក្រាបការត្រួតត្រាពួកស្រុកដើមទ្រាវិឌ។ បន្ទាប់មកមានពួកអ្នកកាន់សាសនាអ៊ីស្លាមដែលបានបង្កើតសន្តតិវង្ស Mughul ក្នុងសតវត្សទី១៣។ បន្ទាប់មកទៀតក្នុងសតវត្សទី១៨ ចក្រភពអង់គ្លេសបានត្រួតត្រាប្រទេសឥណ្ឌា។

ការផ្លាស់ប្ដូរវប្បធម៌ដែលបាននាំមកដោយពួកអារ្យ៉ន បានបង្កើតឥទ្ធិពលអប់រំ និងសង្គមដ៏មានអំណាចដែលបានបន្តមកដល់សព្វថ្ងៃ។ ពួកអារ្យ៉ន បាននាំមកនូវសាសនាព្រាហ្មណ៍ និងវណ្ណៈសង្គមដ៏ខ្ពង់ខ្ពស់របស់គេ ដែលគេបានហៅថា ប្រព័ន្ធវណ្ណៈ។

**គ-សាសនាឥណ្ឌា**

សាសនាឥណ្ឌាដែលជាកម្លាំងដ៏មានឥទ្ធិពលមួយនៅក្នុងប្រទេសឥណ្ឌានោះ រួមបញ្ចូលទាំងជំនឿសាសនាដ៏ទូលំទូលាយមួយ និងទម្លាប់ដ៏ល្អិតល្អន់ទាំងឡាយ។ សាសនាឥណ្ឌាសង្កត់ធ្ងន់ទៅលើការផ្លាស់ប្ដូរនៃព្រលឹង គឺព្រលឹងរបស់មនុស្សម្នាក់ បានឆ្លងកាត់ការចាប់បដិសន្ធិជាថ្មីជាច្រើន ហើយតំណែងរបស់មនុស្សម្នាក់នៅក្នុងកម្រិតលោកធាតុអាស្រ័យទៅលើមនុស្សម្នាក់ប្រកាន់នូវករណីយកិច្ច និងទម្លាប់បានល្អយ៉ាងដូចម្ដេច។ ការចាប់បដិសន្ធិជាថ្មី បញ្ចប់តែនៅពេលដែលព្រលឹងបានឈានដល់កម្រិតខាងផ្លូវចិត្ត ឬស្មារតីខ្ពស់បំផុត ហើយត្រូវបានស្រូបទាញឡើងវិញដោយព្រះព្រហ្ម ដែលជាអំណាចមកពីអាទិទេព។

(នៅមានត)

អនុបណ្ឌិត **សួរ សុធីរ**

## តើព្យាង្គ និងពាក្យខុសគ្នាដូចម្ដេច?

មនុស្សជាទូទៅតែងយល់ថា ព្យាង្គ និងពាក្យមានអត្ថន័យដូចគ្នា។ ដូច្នេះ ដើម្បីឱ្យអស់ចម្ងល់ ចូរពិនិត្យអត្ថន័យព្យាង្គ និងពាក្យដូចខាងក្រោម៖

ព្យាង្គ  គឺសំឡេងចេញមកម្ដង ទោះមានន័យក្ដី មិនមានន័យក្ដី។

ឧទាហរណ៍៖ ក គ បង សុំ ទៅ ឆាន់ ឮ។

ពាក្យ  គឺសំឡេងចេញមកម្ដងក្ដី ឬច្រើនដងក្ដី តែមានន័យគ្រប់គ្រាន់។

ឧទាហរណ៍៖ (ពាក្យ១ព្យាង្គ) ក ខ ឈប់ គិត ពាញ, (ពាក្យពីរព្យាង្គ) សំដី សម្រស់ ប្រសាសន៍ សម្បត្តិ (ពាក្យបីព្យាង្គ) អន្តរធាន វិនិច្ឆ័យ កេងប្រវ័ញ្ច (ពាក្យបួនព្យាង្គ) មមើមមាយ អណ្ដែតអណ្ដូង ឆព្វណ្ណរង្សី...។

**រាជបណ្ឌិត្យសភា**



# មិត្តកុមារ

## តើអ្វីខ្លះដែលជួយអនុគ្រោះដល់ការអភិវឌ្ឍរបស់កុមារ? (តចប់)

### តើគ្រូបង្រៀនកុមារយ៉ាងដូចម្ដេច?

ជាធម្មតា កុមារសកម្មពីធម្មជាតិ ហើយគេរៀនដោយធ្វើសកម្មភាព និងអនុវត្តផ្ទាល់ដៃ។ កុមារដែលប្រកាន់យកស្ថានភាពរៀនសូត្រអសកម្ម នឹងជួបការលំបាកក្នុងការកសាងចំណេះដឹង។ គ្រូបង្រៀនត្រូវតែអនុវត្តគរុកោសល្យដែលមានចរិតលក្ខណៈដូចតទៅ៖

**- <u>លំនាំបង្រៀនត្រូវសម្របសម្រួលទៅតាមកុមារម្នាក់ៗ</u>**

លំនាំគរុកោសល្យត្រូវតែសម្របសម្រួលទៅតាមកុមារតូចៗ និងស្របទៅតាមសមត្ថភាពរបស់គេ។ កុមារម្នាក់ៗអភិវឌ្ឍទៅតាមចង្វាក់របស់គេផ្ទាល់ ដូចនេះវិធីបង្រៀនត្រូវគិតដល់ភាពទីទៃពីគ្នា វ័យ និងសមត្ថភាពផ្ទាល់របស់កុមារម្នាក់ៗ។ កុមារខ្លះឆាប់ទទួលអ្វីៗ ឬមានការចងចាំតាមរយៈការឋាតាម ឬការនិយាយ ខ្លះទៀតគ្រាន់តែឃើញ ឬគ្រាន់តែស្តាប់ក៏មាន។

**- <u>លំនាំបង្រៀនដែលមានន័យ និងទាក់ទាញចំពោះកុមារ</u>**

គ្រូត្រូវឱ្យន័យទៅលើសកម្មភាពទាំងអស់ដើម្បីជំរុញលើកទឹកចិត្តកុមារ។ កុមារត្រូវដឹងជានិច្ច អំពីអ្វីដែលគេធ្វើ អំពីវិស័យដែលគេធ្វើ អំពីអ្វីដែលគ្រូចង់បានពីគេ និងអំពីអ្វីៗដែលគេបានរៀន។ គ្រូមិនត្រូវភ្លេចទេ ក្នុងការជួយជំរុញកុមារឱ្យធ្វើការ។ ការងារនេះត្រូវពឹងផ្អែកលើកាពប៉ិនប្រសប់របស់លោកគ្រូ អ្នកគ្រូក្នុងការស្នើសុំ ឬសំណូមពរឱ្យកុមារតូចៗជួយធ្វើកិច្ចការស្រាលៗនៅក្នុងថ្នាក់រៀនដើម្បីឱ្យកុមារមានទម្លាប់ល្អទាំងនៅក្នុងថ្នាក់ ទាំងនៅក្នុងគ្រួសារ។

**- <u>លំនាំបង្រៀនដែលរៀបចំបានល្អ</u>**

តើលំនាំបង្រៀនណាខ្លះដែលសមស្របដើម្បីរៀបចំការសិក្សាទាំងនេះ?

គ្រូបង្រៀនគប្បីសាកល្បង ឬអនុវត្តលំនាំបង្រៀនដែលប្រព្រឹត្តទៅ៖

- ជុំវិញប្រធានបទមួយ ឬផលប្រយោជន៍ស្នូលមួយ ឬប្រធានបទសិក្សាមួយដូចជា រុក្ខជាតិ ស្លឹក ផ្លែឈើ សត្វ តួអង្គរឿងតាមការស្រមើស្រមៃ...។ លំនាំនេះនាំឱ្យកុមារចេះផ្តល់ន័យដល់សកម្មភាពរបស់ពួកគេរៀន រៀបចំចំណេះដឹង និងធ្វើការផ្សារភ្ជាប់គ្នា។ កុមារអាចរក្សាទុកការអភិវឌ្ឍផ្នែកចំណង់ចំណូលចិត្ត ឬគោលគំនិតរបស់គេទៀតផង។
- ជុំវិញគំរោងមួយ: ការធ្វើឱ្យបានសម្រេចការងារមួយ ការផ្លាស់ប្តូរបទពិសោធ និងទំនាក់ទំនងរវាងថ្នាក់មួយទៅថ្នាក់មួយទៀត ការតាំងពិព័រណ៍...។
- ការសិក្សាដោយផ្តើមចេញពីល្បែង: ល្បែងសិក្សាផ្សេងៗ ល្បែងគណិតវិទ្យា...។
- ការសិក្សាដោយផ្តើមចេញពីស្ថានភាពដែលបង្កើតឡើង: ការអានសៀវភៅកម្រងរូបភាព និងទំនាក់ទំនងក្នុងបរិបទមួយសម្រាប់សកម្មភាពផ្សេងៗក្នុងមុខវិជ្ជាផ្សេងទៀត...។
- ការសិក្សាដោយផ្តើមចេញពីសកម្មភាពប្រចាំថ្ងៃ: ទម្លាប់មកដល់ថ្នាក់រៀនទៀងពេលវេលា មានសុជីវធម៌ល្អ ស្គាល់ឈ្មោះ ថ្ងៃ ខែ ចេះរាប់លេខ...។

- **លំនាំបង្រៀនដែលសកម្ម និងសំបូរបែប**

ធម្មតាកុមាររពឹស ឆាប់ទទួលយកណាស់។ កុមារកសាងចំណេះដឹងតាមរយៈសកម្មភាព និងធ្វើសកម្មភាពជាមួយអ្នកឯទៀត។ គ្រូត្រូវបង្ហាញសកម្មភាពទាំងឡាយណាដែលកុមារអាចធ្វើសកម្មភាពផ្ទាល់ដៃ ដោយសង្កត់ធ្ងន់ទៅលើជីវភាពប្រចាំថ្ងៃរបស់សិស្ស។ សកម្មភាពទាំងនេះត្រូវផ្លាស់ប្តូរទៅតាមពេលវេលា និងទៅតាមទម្រង់របស់វា។

- **លំនាំបង្រៀនដែលផ្អែកលើសកម្មភាព និងការពិចារណា**

តាមរយៈការផ្លាស់ប្តូរបទពិសោធរវាងបុគ្គល និងបុគ្គល គ្រូជួយសម្រួលការពិចារណា ជួយកុមារឱ្យកសាងបាននូវក្បួនច្បាប់មួយចំនួន។ ក្នុងរយៈពេលនៃការសិក្សា គ្រូត្រូវជួយជំរុញឱ្យចេះពន្យល់ ចេះប្រើពាក្យឱ្យត្រូវទៅតាមសកម្មភាពរបស់គេ ឱ្យគេផ្តល់បញ្ញត្តិផ្សេងៗ។

- **លំនាំបង្រៀនដែលបង្កលក្ខណៈងាយស្រួលដល់ការពិភាក្សាផ្លាស់ប្តូរយោបល់**

កសាងចំណេះដឹង និងធ្វើការជាមួយអ្នកឯទៀត ផ្តល់លក្ខណៈងាយស្រួលដល់ភាពម្ចាស់ការ និងការផ្លាស់ប្តូរបទពិសោធ និងពិភាក្សាផ្លាស់ប្តូរយោបល់ (ទំនាក់ទំនងក្នុងសង្គម និងភាសា)។

- **លំនាំបង្រៀនដែលផ្តើមចេញពីសកម្មភាពល្បែង**

ចំពោះកុមារ ល្បែងគឺជាធម្មជាតិ និងជាពិភពរបស់ពួកគេ។ កុមារទាំងអស់ចូលចិត្តលេង ធ្វើអ្វីៗដោយដៃមានការងារកាត់ បត់ បិទ គូរ សាងសង់...។ គ្រូត្រូវយកចិត្តទុកដាក់ប្រើប្រាស់មធ្យោបាយនេះដើម្បីផ្តល់ឱ្យកុមារនូវលំនាំមួយដែលនាំសិស្សឱ្យរកឃើញនូវយុទ្ធវិធីមួយ ឱ្យសិស្សគោរពក្បួនច្បាប់ ឱ្យពន្យល់ពីអ្វីៗ ឱ្យប្រើពាក្យឱ្យត្រូវនឹងអ្វីដែលគេធ្វើ ឱ្យតាងសកម្មភាពរបស់ពួកគេ ឱ្យផ្តល់បញ្ញត្តិផ្សេងៗ...។

ល្បែងមានតួនាទីសំខាន់ណាស់ក្នុងការសិក្សា។ ជាការពិតណាស់ ល្បែងជាប្រភពនៃការសប្បាយរបស់កុមារ ជាពិសេសគឺជាមធ្យោបាយយ៉ាងជិតដិតរបស់កុមារក្នុងការសិក្សា។

គ្រូត្រូវបង្កើតទំនាក់ទំនងរវាងល្បែង និងសកម្មភាពសិក្សាបន្តិចម្តងៗ ដែលប្រការនេះអាចនាំឱ្យកុមាររីកចម្រើន ហើយក្លាយជាសិស្សដែលចូលចិត្តរៀន។

<u>ល្បែង និងសកម្មភាពពាក់ព័ន្ធ</u>




*ដកស្រង់ដោយលោកស្រី* **ម៉ុន សារ៉ន**

# ការបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈជំទង់

**១-ការប្រែប្រួលបុគ្គលិកលក្ខណៈ**

**ក**-ចំណុចដែលគួរឱ្យកត់សម្គាល់នៅវ័យនេះ គឺភាពគ្រប់ការ។ ភាពគ្រប់ការនេះជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រែប្រួលបុគ្គលិកលក្ខណៈរបស់ជំទង់។ គ្រូ ឬអ្នកអប់រំត្រូវតែមានការយល់ដឹងឱ្យបានច្បាស់នូវលក្ខណៈរបស់ជំទង់។

**ខ**-នៅដំណាក់នេះ ជំទង់ដឹងថាខ្លួនគេចូលក្នុងដំណាក់ថ្មីមួយនៃជីវិត ហើយគេមានតម្រូវការថ្មី ចិត្តរំភើបថ្មី សញ្ចេតនាថ្មី អត្តចរិតថ្មី ការគិតថ្មី ចំណង់ចំណូលចិត្តថ្មី ចិត្តគំនិតថ្មី បំណងប្រាថ្នាថ្មី...។ បើយើងប្រៀបធៀបសកម្មភាពជំទង់ទៅនឹងសកម្មភាពកុមារ យើងឃើញថា សកម្មភាពសំខាន់ៗរបស់ជំទង់ផ្លាស់ប្ដូរ។ ចំពោះជំទង់សកម្មភាពដ៏សំខាន់ជាងគេ គឺការសិក្សា បន្ទាប់មកគឺការធ្វើពលកម្ម និងល្បែង។ ជានិច្ចកាលជំទង់បានជួបប្រទះលក្ខខណ្ឌសកម្មភាពបញ្ហាថ្មីៗដូចជាការសេពគប់មិត្តភក្តិ។ ជំទង់ជួបប្រទះបញ្ហាថ្មីៗជាច្រើនតាមមុខវិជ្ជា ហើយជំទង់កំពុងតែបណ្ដុះបណ្ដាលបញ្ញត្តិផ្ទាល់ខ្លួនដែលសម្បូរទៅដោយសញ្ញាណអរូបីតាមមុខវិជ្ជានីមួយៗ។

ឧទាហរណ៍ៈ ការសិក្សាតម្រង់ទៅសញ្ញាណអរូបី មុខវិជ្ជាបង្រៀនចាប់ផ្ដើមដាច់ចេញពីគ្នា។ កាលនៅបឋមសិក្សា កុមារសិក្សានូវមូលដ្ឋានភាសាជាតិជាចម្បង រួមទាំងគណិតវិទ្យា និងសញ្ញាណខ្លះនៃវិទ្យាសាស្ត្រ។ ប៉ុន្តែនៅមធ្យមសិក្សាបឋមភូមិ គេត្រូវការសិក្សាមុខវិជ្ជាច្រើន។ ក្រៅពីអក្សរសាស្ត្រ និងគណិតវិទ្យា គេសិក្សាពីប្រវត្តិវិទ្យា ភូមិវិទ្យា ជីវវិទ្យា... ហើយនៅក្នុងគណិតវិទ្យា មានលេខគណិត ពីជគណិត និងធរណីមាត្រ។

ជំទង់ចាប់ផ្ដើមសិក្សាជាមួយគ្រូច្រើននាក់តាមមុខវិជ្ជាផ្សេងៗគ្នា។ ពេលនេះជំទង់ចាប់ផ្ដើមមានឧត្តមគតិ ហើយមនុស្សដែលជាគំរូរបស់គេនៅពេលនេះ មិនមែនគ្រូរបស់គេតែមួយគត់នោះទេ។ កាលនៅមត្តេយ្យសិក្សា និងបឋមសិក្សា គ្រូជាជនគំរូរបស់កុមារ ជាមនុស្សដែលល្អជាងគេចំពោះពួកគេ។ តែមកដល់ពេលនេះ នៅមធ្យមសិក្សាជនគំរូសម្រាប់ជំទង់គឺមនុស្សពិតៗដូចជាតួអង្គនៅក្នុងប្រលោមលោក ក្នុងខ្សែភាពយន្ត អ្នកចម្រៀង ឬតួចម្រៀងកាយវិការ ឬកីឡាករជើងឯកដែលជាជនគំរូសម្រាប់ពួកគេឯណោះវិញទេ។ ពេលណាគេអានរឿងប្រលោមលោក ឬមើលខ្សែភាពយន្ត ឬវីដេអូ ហើយជួបនឹងវីរភាពតួអង្គណាមួយគេនឹងស្ងើចសរសើរដល់វីរជននោះ ហើយគេចង់ធ្វើខ្លួនឱ្យទៅជាវីរជន។ ដូចនេះ គ្រូត្រូវជួយជំទង់ឱ្យបណ្ដុះបណ្ដាលឧត្តមគតិនៃជីវិត។

វ័យជំទង់ជាវ័យដែលអនុគ្រោះបំផុតដល់ការសិក្សា ព្រោះសមត្ថភាពបញ្ញារបស់គេនៅពេលនេះមានការរីកចម្រើនខ្លាំងក្លា ពិសេសគឺ «ការគិតអរូបី»។ គ្រូត្រូវបណ្ដុះឧត្តមគតិដល់ជំទង់ដើម្បីឱ្យគេយល់តម្លៃក្នុងឆាកជីវិត ព្រោះថាវ័យនេះការស្រមើស្រមៃ និងឧត្តមគតិមិនទាន់មានស្ថិរភាពនៅឡើយទេ ហើយអាចមានការប្រែប្រួលយ៉ាងឆាប់រហ័សផង។ ពេលនេះជំទង់ចង់ឃើញ ចង់ដឹង ចង់ពិចារណា ចង់ពិភាក្សា ចង់វែកញែក ចង់យកឈ្នះ ទោះបីជាសកម្មភាពខ្លះជាការខុសឆ្គងក៏ដោយ។ កម្មវត្ថុនៃការសិក្សាមានភាពទូលំទូលាយ អាចឱ្យជំទង់ធ្វើការស្វែងយល់ និងមានការពិភាក្សាទៅលើបញ្ហាសង្គមទៀតផង។

ឧទាហរណ៍ៈ ជំទង់អាចពិភាក្សាទៅលើ «បុគ្គលនិយម» និង «សមូហភាព»។

ក្រៅពីចរិតលក្ខណៈខាងលើ ជំទង់មានលក្ខណៈគួរឱ្យកត់សម្គាល់ជាងគេ គឺអំណះអំណាងបុគ្គលិកលក្ខណៈដែលជាតម្រូវការចាំបាច់មួយរបស់ជំទង់។ តម្រូវការនោះសម្ដែងចេញក្នុងទំនាក់ទំនងសង្គម។

**២-ទំនាក់ទំនងជាមួយសង្គម**

**ក.ទំនាក់ទំនងជាមួយមនុស្សពេញវ័យ**

- ជាមួយគ្រួសារ នៅក្នុងគ្រួសារ ឪពុកម្ដាយ ឬបងប្រុសស្រីមិនត្រូវចាត់ទុកជំទង់ជាក្មេងទៀតទេ។ គេត្រូវផ្ដល់

សេរីភាព និងភាពឯករាជ្យដល់ជំទង់ខ្លះ និងប្រគល់កិច្ចការណាដែលធំដុំដល់គេផង។ ជំទង់ទាមទាសេរីភាព និងភាពម្ចាស់ការ និងភាពស្វ័យសម្រេចលើអ្វីៗដោយខ្លួនគេផ្ទាល់។ មាតាបិតា ឬបងប្រុសស្រី ត្រូវប្រគល់ការកិច្ចឱ្យគេទទួលខុសត្រូវនូវកិច្ចការណាជួនល្មម ដោយធ្វើការតាមជានសកម្មភាពជំទង់ឱ្យបានជិតដល់ផង។ ជំទង់ពេលនេះ ចេះធ្វើឱ្យឪពុកម្តាយមានទំនុកចិត្តលើគេបានខ្លះហើយ។ ជំទង់មិនចង់ឱ្យអ្នកណាចាត់ទុកគេដូចក្មេងទៀតទេ។ ការថ្នាក់ថ្នម ការលួងលោមរបស់ឪពុកម្តាយ ធ្វើឱ្យគេធុញទ្រាន់ក្នុងពេលនេះ តែគេចង់ឱ្យឪពុកម្តាយគេគោរពសិទ្ធិគេវិញ ដូចជាការផ្តល់សេរីភាពដល់ពួកគេ។ ក្នុងករណីណាដែលបុគ្គលិកលក្ខណៈរបស់គេមិនត្រូវបានគេគោរពនោះ ជំទង់នឹងបង្កជម្លោះជាមួយអ្នកនោះ ពិសេសជាមួយមនុស្សពេញវ័យ។

- ជាមួយគ្រូ ជាការពិតហើយថា ក្នុងដំណាក់នេះ ជំទង់តែងតែគិតថា គ្រូជាអ្នកផ្តល់ចំណេះដឹងដល់ពួកគេ ហើយគ្រប់អាកប្បកិរិយារបស់គ្រូធ្វើឱ្យគេគោរព។ តែគ្រូមិនមែនជាជនគំរូដូចកាលគេនៅបឋមសិក្សានោះទៀតទេ។ គេគោរពគ្រូក្នុងនាមជាអ្នកអប់រំ អ្នកបង្ហាត់បង្រៀនមុខវិជ្ជាសិក្សាប៉ុណ្ណោះ។ តែជាទូទៅជំទង់តែងតែមានចរិតគោរពស្រឡាញ់គ្រូ។

- ជាមួយមតិសាធារណៈ ជំទង់ចាប់អារម្មណ៍ណាស់ចំពោះការរិះគន់ និងការវាយតម្លៃពីមតិសាធារណៈ។ ជំទង់ចង់បានការសរសើរពីអ្នកដទៃ តែគេខ្លាចការរិះគន់ពីអ្នកដទៃ ផ្ទុយទៅវិញគេហ៊ានរិះគន់អ្នកដទៃយ៉ាងខ្លាំងក្លា ហេតុហ៊ានបង្កជម្លោះផង។ គេចូលចិត្តគ្រាប់តាមមនុស្សធំ គេចង់ដឹងរឿងមនុស្ស ពិសេសទំនាក់ទំនងរវាងបុរស និងនារី តែជំទង់ហាក់ដូចជាមិនទាន់អើពើនៅឡើយ។

ជំទង់ប្រាថ្នាចង់ឱ្យបានដូចលក្ខខណ្ឌមនុស្សពេញវ័យ «គេចង់ក្លាយជាមនុស្សពេញវ័យ»។ ហេតុនេះហើយបានជាជំទង់ចូលចិត្តប្រណាំងប្រជែងជាមួយមនុស្សពេញវ័យ។ ជំទង់ចង់យកឈ្នះអ្នកដទៃណាស់។ ពិសេសជំទង់ចង់បញ្ជាទៅកុមារក្នុងឋានៈគេជារៀមច្បង។ ជានិច្ចកាល ជំទង់ចៀសវាងសកម្មភាពណាដែលឡូកឡំជាមួយកុមារ។

**ខ.ទំនាក់ទំនងជាមួយសហគមន៍**

ក្នុងសកម្មភាពសហគមន៍ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សង្គម ជំទង់ចេះគោរពស្មារតីសមូហភាពផ្តល់កិត្តិយសសម្រាប់សហគមន៍ ហើយគេតែងតែបញ្ចេញភាពសង្ហានៅក្នុងចំណោមសហគមន៍។ ជំទង់មានស្មារតីទទួលខុសត្រូវចំពោះសមូហភាព បើកាលណាសមូហភាពនោះមានការចាត់តាំងល្អ មានសកម្មភាពប្លែកៗដែលជាទីចាប់អារម្មណ៍ ពិសេសប្រសិនបើសមាជិកទាំងអស់មានស្មារតីសកម្មប្រយុទ្ធ នោះគេនឹងចូលរួមដោយស្មោះស្ម័គ្រ។ ផ្ទុយទៅវិញបើសិនជាសហគមន៍នោះដឹកនាំមិនល្អ ចាត់តាំងមិនល្អ ជំទង់នឹងចាកចោលសហគមន៍នោះហើយទៅបង្កើតជាក្រុមមួយដែលមានជីវភាពរស់នៅតាមចំណង់ចំណូលចិត្តរបស់គេវិញ។

**គ.ទំនាក់ទំនងជាមួយមិត្តភក្តិ**

ដោយមានការលូតលាស់ខ្លាំងក្លាផ្នែកសញ្ចេតនា ជំទង់មានតម្រូវការជំជែងក្នុងទំនាក់ទំនងរវាងគ្នា និងគ្នា ពិសេសគឺការស្វែងរកមិត្តភក្តិជិតស្និទ្ធ។ មិត្តភាពនេះ ជាមិត្តភាពជ្រើសរើស ព្រោះជំទង់ចូលចិត្តស្រឡាញ់មិត្តណាដែលមានចំណង់ចំណូលចិត្តដូចគ្នា ស្មោះត្រង់ជិតស្និទ្ធ និងទុកចិត្តគ្នាទៅវិញទៅមក ជាមិត្តចិត្តមួយថ្លើមមួយរបស់គេ។

ក្នុងទំនាក់ទំនងនេះ មានចំណុចមួយគួរឱ្យកត់សម្គាល់ខ្លាំងជាងគេ គឺទំនាក់ទំនងរវាងជំទង់បុរស និងជំទង់ស្ត្រី។ ដំបូងទំនាក់ទំនងរវាងភេទទាំងពីរនេះលេចចេញជាទំនាស់ និងការរិះគន់ទៅវិញទៅមក។ ប៉ុន្តែនៅអាយុ១៥-១៦ឆ្នាំមានសភាពពិសេសមួយកើតឡើង ដែលចិត្តវិទូហៅថា «មិត្តភាពស្នេហា» ព្រោះពេលនេះវាស្រុះស្រួលគ្នា និងខិតរកគ្នា។ ប៉ុន្តែមិត្តភាពនេះត្រូវបានគេបាត់បង់ធាតុដើមបន្តិចហើយ ពីព្រោះវាបានបង្កប់នូវសេចក្តីស្នេហានៅក្នុងនោះ តែសេចក្តីស្នេហានេះពុំទាន់ចេញជារូបរាងច្បាស់លាស់ និងពុំទាន់ហ៊ានប្រកាសនៅឡើយទេ។ មិត្តភាពស្នេហានេះអាចកើតឡើងពីការចំអែចំអន់ ដំបូងគ្រាន់តែជាការសើចលេងកំសាន្តពីក្នុងចំណោមមិត្តភក្តិរបស់គេប៉ុណ្ណោះ។ ចំណង

មិត្តភាពស្នេហានេះបង្កប់នូវមនោសញ្ចេតនាដ៏ជ្រាលជ្រៅ តែគេហាក់ដូចជានៅមានការអៀនខ្មាសរៀងៗខ្លួន ហើយគេមិនហ៊ានប្រកាសជាចំហនូវសេចក្តីស្នេហានៅឡើយ។ អ្វីដែលជំទង់ឈឺចាប់ខ្លាំងជាងគេនោះគឺ ភាពបរាជ័យក្នុងបញ្ហាស្នេហា។

នេះគឺជាបញ្ហាមួយដែលគ្រូគួរចាប់អារម្មណ៍ ព្រោះការជំរុញ ឬការហាមមិនឱ្យមាន «មិត្តភាពស្នេហា» ជាបញ្ហាមួយពិបាកខ្លាំង។ ក្នុងករណីនេះ ជាបឋមគេមិនត្រូវបង្ក្រាបទាំងកំពេលនោះទេ គេត្រូវអប់រំ ឬបង្វែរជំទង់ទៅរកសកម្មភាពផ្សេងៗវិញដូចជា សកម្មភាពនៃការសិក្សា ឬសកម្មភាពកីឡា សកម្មភាពសិល្បៈជាដើម ដើម្បីកាត់បន្ថយអារម្មណ៍របស់ពួកគេ និងជាមធ្យោបាយសម្រាប់ដោះស្រាយដ៏មានប្រសិទ្ធភាពលើបញ្ហានេះ។

ជំទង់នៅមានចរិតលក្ខណៈរួមខ្លះទៀតដូចជា៖

- គំនិតម្ចាស់ការ គំនិតនេះសម្តែងចេញតាមរយៈការចចេស ឬមានះ ជាមួយមនុស្សចាស់ ឬជាមួយគ្រូរបស់គេ។ ប្រការទាំងនេះជាបុព្វហេតុនៃជម្លោះ និងទំនាស់។ ជំទង់មិនត្រូវការដំបូន្មានពីអ្នកដទៃទៀតទេ គេធ្វើអ្វីៗតាមការយល់ឃើញរបស់គេ។ គេអាចគ្រប់គ្រងខ្លួនគេ គេមានស្មារតីម្ចាស់ការ ការទទួលខុសត្រូវដោយយល់ថា គេអាចស្វែងរកសុភមង្គលបានដោយខ្លួនគេ។

- ចិត្តរំភើបខ្លាំង ជំទង់មានចិត្តរំភើបខ្លាំងដែលពិបាកនឹងទប់កុំឱ្យមាន។ ប៉ុន្តែនៅក្នុងវ័យនេះ ជំទង់ចាប់ផ្តើមមានឆន្ទៈ ហើយមានការអប់រំដោយប្រើការពន្យល់លួងលោមណែនាំគេ ទើបអាចបង្ក្រាបកម្លាំងចិត្តរំភើប និងសញ្ចេតនារបស់ជំទង់បាន។

- ការស្រមៃ និងឧត្តមគតិ ជំទង់មានការស្រមៃច្រើន។ ប៉ុន្តែការស្រមៃនេះនៅមានការប្រែប្រួល។ នៅវ័យនេះគេចាប់ផ្តើមមានឧត្តមគតិ តែឧត្តមគតិនេះមានភាពអណ្តែតអណ្តូងនិយម ច្រើនជាងប្រាកដនិយម។

ឧទាហរណ៍ : ម្តងគេចង់ក្លាយទៅជាអវកាសយានិក ម្តងគេចង់ក្លាយទៅជាកីឡាករ ម្តងវាចង់ក្លាយទៅជាអ្នកប្រាជ្ញ ឬសិល្បករ ឬជាតួចម្រៀងកាយវិការ...។

**៣.ការអប់រំជំទង់**

**ក.**ជាបឋម យើងត្រូវយល់ឱ្យច្បាស់ពីជំទង់ គឺយល់ពីចរិតលក្ខណៈនៅក្នុងវ័យនេះដូចជា៖

- ភាពគ្រប់ការ
- ការប្រែប្រួលផ្នែកសមត្ថភាព
- ការប្រែប្រួលផ្នែកទំនាក់ទំនងក្នុងសង្គម
- អំណះអំណាងនៃបុគ្គលិកលក្ខណៈដូចជា ទំនាក់ទំនងនៅក្នុងសង្គមរបស់ជំទង់។

**ខ.**យើងត្រូវពឹងផ្អែកលើចរិតលក្ខណៈទាំងនេះ ដើម្បីអប់រំជំទង់ដូចជាត្រូវចេះគោរពបុគ្គលិកលក្ខណៈរបស់ជំទង់ និងចៀសវាងការចាត់ទុកជំទង់ជាកុមារទៀត ព្រមទាំងប្រគល់ការងារឱ្យបានសក្តិសមទៅនឹងសមត្ថភាពដូចជាឱ្យជំទង់ដឹកនាំក្មេងៗ ជួយការងារយុវជន និងមនុស្សពេញវ័យ។ គ្រូគួរចៀសវាង ធ្វើឱ្យគេបាត់បង់នូវ «អស្មិមានះ» ព្រោះអាចបណ្តាលឱ្យគេចាកចេញពីគ្រួសារទៅរស់នៅដោយខ្លួនឯង ជួនកាលក្លាយជាជនពាលាអាវាសែ។

**គ.**ត្រូវចេះលើកសរសើរជំទង់ចំពោះសកម្មភាពដែលល្អ ព្រោះជំទង់ចូលចិត្តការសរសើរ។ ប្រសិនបើជាយើងសរសើរនោះគេនឹងធ្វើសកម្មភាពបានកាន់តែល្អឡើងៗថែមទៀត។

**ឃ.**ដើម្បីឱ្យជំទង់មានឧត្តមគតិ និងការស្រមើស្រមៃរីកចម្រើន អ្នកអប់រំត្រូវបំផុសឱ្យជំទង់អានរឿងព្រេង ឬរឿងនិទានដែលឆ្លុះបញ្ចាំងពីគំរូវីរភាពពិតៗក្នុងសង្គម ឬអប់រំដោយបង្ហាញគំរូមនុស្សពិត។ ជាមួយគ្នានេះដែរ អ្នកអប់រំត្រូវជួយណែនាំជំទង់ក្នុងរបៀបស្វ័យសិក្សា ដើម្បីពង្រឹងឆន្ទៈដល់ជំទង់ ព្រោះនៅវ័យនេះគំនិតអាចបញ្ឆាចិត្តគេបាន។ ដើម្បីជួយជំទង់ឱ្យឆ្លងដល់យុវជន គ្រូត្រូវលើកយកមកនិយាយផងដែរនូវបញ្ហា «មិត្តភាពស្នេហា» ដោយល្បិចគរុកោសល្យ៕

**ឯកសារនាយកដ្ឋានបណ្តុះបណ្តាល និងក្រឹតការ**




## ការបង្រៀនវិទ្យាសាស្ត្រអនុវត្តនៅបឋមសិក្សា (ត)

**<u>មេរៀនទី១</u>**

### ចំណែកថ្នាក់សត្វ

ដើម្បីបង្រៀនមេរៀននេះប្រកបដោយគុណភាព និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូគប្បីស្វែងយល់ឱ្យបានស៊ីជម្រៅនូវចំណុចមួយចំនួនដូចខាងក្រោម។

ក្នុងចំណោមសត្វទាំងអស់នៅលើផែនដីមានសត្វខ្លះជាមំសាសី (ស៊ីសាច់ធ្វើជាអាហារ) ខ្លះជាតិណាសី (ស៊ីសត្វល្អិត) ខ្លះជារុក្ខាសី (ស៊ីរុក្ខជាតិ ឬគ្រាប់ធញ្ញជាតិ) និងខ្លះទៀតជា សព្វាសី (ស៊ីអាហារគ្រប់មុខ)។

សត្វខ្លះត្រូវការចំណីអាហារដាច់ដោយឡែកពីគេ ដូចជាពួកឃ្មុំត្រូវការលំអងផ្កា និងសារជាតិផ្សេងៗដែលមានរសជាតិផ្អែមដើម្បីចិញ្ចឹមជីវិត។ សត្វខ្លះជាប្រភេទសត្វប្រមាញ់ ខ្លះជាប្រភេទសត្វជញ្ជូនអាហារទុក ខ្លះទៀតជាប្រភេទសត្វផ្សេងពីសត្វទាំងពីរប្រភេទនេះ។ សត្វខ្លះរកស៊ីពេលយប់ ខ្លះរកស៊ីពេលថ្ងៃ ខ្លះមានជម្រក (កណ្ដុរ កណ្ដៀរ...) ខ្លះគ្មានជម្រក (សត្វល្អិត និងសត្វចតុប្បាទ)។ សត្វភាគច្រើនមានលក្ខណៈសម្គាល់ផ្សេងៗគ្នា។

<u>ឧទាហរណ៍:</u>

| លក្ខណៈសម្គាល់ | ក្ងាន | ទា | មាន់ | គោ | ក្ដាន់ | ឆ្កែ |
|---|---|---|---|---|---|---|
| រោមស្លាប | X | X | X | | | |
| ជើងមានម្រាមជាប់គ្នា | X | X | | | | |
| រោម | | | | X | X | X |
| ស្លឹកត្រចៀក | | | | X | X | X |
| ស្នែង | | | | X | X | |

លក្ខណៈសម្គាល់នីមួយៗខាងលើនេះ អាចឱ្យយើងដឹងពីរបៀបផ្ដុំសត្វទាំងនោះទៅតាមក្រុម នៅក្នុងប្រអប់ដែលមានលក្ខណៈសម្គាល់ដូចគ្នា៖




- លក្ខណៈសម្គាល់ «រោមស្លាប» អាចឱ្យយើងផ្គុំ មាន់ ក្ងាន និងទា ជាក្រុម «ក»។
- លក្ខណៈសម្គាល់ «ជើងមានស្រោមជាប់គ្នា» អាចឱ្យយើងផ្គុំ ក្ងាន និងទា ជាក្រុម «ខ»។
- លក្ខណៈសម្គាល់ «រោម» អាចឱ្យយើងផ្គុំ ឆ្កែ គោ និងក្ដាន់ ជាក្រុម «គ»។
- លក្ខណៈសម្គាល់ «ស្នែង» អាចឱ្យយើងផ្គុំ គោ និងក្ដាន់ ជាក្រុម «ឃ»។

តាមលទ្ធផលខាងលើនេះ យើងអាចធ្វើចំណែកថ្នាក់សត្វតាមទម្រង់ «មែកឈើ» ដែលបង្ហាញឱ្យឃើញពីដូនតារួមរបស់ក្រុមសត្វនីមួយៗ៖




- ក្រុម «ក» ៖ មាន់ ក្ងាន ទា បង្ហាញពីដូនតារួមមួយដែលមានលក្ខណៈសម្គាល់ដូចគ្នា គឺ «មានរោមស្លាប»
- ក្រុម «ខ» ៖ ក្ងាន ទា បង្ហាញពីដូនតារួមមួយដែលមានលក្ខណៈសម្គាល់ដូចគ្នា គឺ «ជើងមានស្រោមជាប់គ្នា»
- ក្រុម «គ» ៖ ឆ្កែ គោ ក្ដាន់ បង្ហាញពីដូនតារួមមួយដែលមានលក្ខណៈសម្គាល់ដូចគ្នាគឺ «មានរោម និងដោះ»
- ក្រុម «ឃ» ៖ គោ ក្ដាន់ បង្ហាញពីដូនតារួមមួយដែលមានលក្ខណៈសម្គាល់ដូចគ្នាគឺ «មានស្នែង»។

ការធ្វើចំណែកថ្នាក់សត្វ មានន័យថា ការប្រមូលផ្ដុំសត្វជាក្រុមទៅតាមលក្ខណៈសម្គាល់រួម (លក្ខណៈរូប) រួចដាក់ឈ្មោះឱ្យក្រុមនីមួយៗ៖

- ក្រុម «ក» ជាក្រុម បក្សី
- ក្រុម «ខ» ជាក្រុម តាលបាទបក្សី
- ក្រុម «គ» ជាក្រុមថនិកសត្វ
- ក្រុម «ឃ» ជាក្រុម សត្វទំពាអៀង។

ការធ្វើចំណែកថ្នាក់សត្វទៅតាមលក្ខណៈសម្គាល់ខាងក្រៅ (លក្ខណៈរូប) មានន័យថាធ្វើចំណែកថ្នាក់ទៅតាមអ្វីដែលសត្វទាំងនោះមាន សត្វដទៃទៀតគ្មាន។

<u>**ឧទាហរណ៍:**</u>

- ពួកសត្វដែលមានរោម និងដោះ ៖ ថ្នាក់ថនិកសត្វ
- ពួកសត្វដែលមានរោមស្លាប និងផ្លាំងស្លាប ៖ ថ្នាក់បក្សី
- ពួកសត្វដែលមានស្រកាលើដងខ្លួន ហើយផ្លាស់ទីដោយ វារ ឬលូន៖ ថ្នាក់លូន
- ពួកសត្វដែលមានស្បែកគ្រាតហើយសើម អវយវៈក្រោយវែងជាងអវយវៈមុខ៖ ថ្នាក់កង្កែប
- ពួកសត្វដែលមានអ៊ែល និងព្រុយប្រកបដោយទ្រនុងឆ្អឹង៖ ថ្នាក់ត្រី។



(នៅមានត)

លោក **ប៊ុន សារិទ្ធ**

# មូលភេទ អ-អិ (តចប់)

ខ.២.ក្បួនទី២

ឧទាហរណ៍៖ គំហុក គ្រហើ ជំហាន ជំហួស ទ្រហោ ព្រហើន...។

វិភាគពាក្យ គំហុក៖ គ ជាពួក អិ ក្នុងក្រុម១ដែលជាក្រុមខ្លាំងឬ «គ ជា អិ១»។

ហ ជាពួក អ ក្នុងក្រុម២ដែលជាក្រុមខ្សោយឬ «ហ ជា អ២»។

ហ ត្រូវប្ដូរមូលភេទតាមមូលភេទរបស់ គ ជាពួក អិ វិញ។

ដូចនេះ៖ គំ (ជាព្យាង្គ អិ) + ហុក (ជាព្យាង្គ អ) > គំហុក (ជាព្យាង្គពួក អិ ទាំងពីរ)។

ទំរង់៖ [ព១សព៣] + [ព១សព៣] > [ព១សព៣ / ព៤សព៦]

រូបមន្ត៖ [ព១សព៣] + [ព១សព៣] > [ព១សព៣ / ព៤សព៦]

ព១ ជា អិ១ ព១ ជា អ២

ព្យាង្គ អិ + ព្យាង្គ អ > ព្យាង្គ អិ / ព្យាង្គ អិ

ក្នុងទីនេះ៖ ព១ មានឥទ្ធិពលនាំ ព៤ អោយប្ដូរមូលភេទជាពួក អិ ដោយមិនបាច់ប្រើវណ្ណយុត្តិ ត្រីស័ព្ទ ( ៊ )។

ក្បួន៖ ក្នុងពាក្យពីរព្យាង្គ កាលណាព្យាង្គ អិ ខាងដើមកើតមកពីសញ្ញាព្យញ្ជនៈ អិ១ ព្យាង្គ អ ខាងចុងដែលកើតមកពីសញ្ញាព្យញ្ជនៈ អ២ (ហ) ត្រូវដូរជាព្យាង្គ អិ វិញ គឺថា ព១ ជាអ្នកកំណត់សូរស្រៈពួក អិ ក្នុងព្យាង្គទាំងពីរ។

ឧទាហរណ៍បញ្ជាក់៖

គំហក គំហកគំហីន គំហុក គំហែត គ្រហរ គ្រហាញ គ្រហិកគ្រហុក គ្រហឹត គ្រហឹម គ្រហុច គ្រហុប គ្រហួ គ្រហើ គ្រហែត គ្រហែម ជង្ហុក ជំហប់ ជំហម ជំហរ ជំហាញ ជំហាន ជំហួស ជំហោង ជំហៅ ជ្រហិតជ្រហម ទំហាត់ ទំហោង ទំហំ ទ្រហឹង ទ្រហោ ព្រហាក់ ព្រហាម ព្រហឹត ប្រហឹតព្រហែត ព្រហូត ព្រហើន...។

**ករណីគ្មានឥទ្ធិពលមូលភេទ**

ក្នុងពាក្យពីរព្យាង្គ ពេលខ្លះ៖ ព១ គ្មានឥទ្ធិពលមូលភេទទៅលើ ព៤ ទេ បានសេចក្ដីថា ព១ ពុំអាចនាំ ព៤ អោយប្ដូរមូលភេទបានឡើយ។

ខ.៣.ក្បួនទី៣

ឧទាហរណ៍៖ ក្រទីក្រទា បង្ហាប់ បាទី សំគាល់ ស្រទប អំពើ...។

វិភាគពាក្យ បាទី៖ ប ជាពួក អ ក្នុងក្រុម១ដែលជាក្រុមខ្លាំងឬ «ប ជា អ១»។

ទ ជាពួក អិ ក្នុងក្រុម១ដែលជាក្រុមខ្លាំងឬ «ទ ជា អិ១»។

ទ រក្សាមូលភេទរបស់ខ្លួនដដែល គឺមូលភេទ អិ។

ដូចនេះ៖ បា (ព្យាង្គ អ) + ទី (ព្យាង្គ អិ) > បាទី (ព្យាង្គ អ / ព្យាង្គ អិ)។

ទំរង់៖ [ព១ស] + [ព១ស] > [ព១ស / ព៤ស]

រូបមន្ត៖ [ព១ស] + [ព១ស] > [ព១ស / ព៤ស]

ព១ ជា អ១ ព១ ជា អិ

ព្យាង្គ អ + ព្យាង្គ អិ > ព្យាង្គ អ / ព្យាង្គ អិ

ក្នុងទីនេះ៖ ព១ ពុំមានឥទ្ធិពលនាំ ព៤ ឱ្យប្ដូរមូលភេទជាពួក អ បានឡើយ។

ក្បួន៖ ក្នុងពាក្យពីរព្យាង្គ កាលណាព្យាង្គ អ ខាងដើមកើតមកពីសញ្ញាព្យញ្ជនៈ អ១ ព្យាង្គ អ៊ ខាងចុងដែលកើតមកពីសញ្ញាព្យញ្ជនៈ អ៊១ ពុំប្រែប្រួលឡើយ គឺថា ព១ និងព៤ ជាអ្នកកំនត់សូរស្រៈក្នុងព្យាង្គរៀងខ្លួន។

ខ.៤.ក្បួនទី៤

ឧទាហរណ៍៖ រហក់ រហង់ រហិតរហៃ រហូត លំហ លំហូរ លំហាច លំហើយ...។

វិភាគពាក្យ រហក់៖ រ ជាពួក អ៊ ក្នុងក្រុម២ ដែលជាក្រុមខ្សោយឬ «រ ជា អ៊២»។

ហ ជាពួក អ ក្នុងក្រុម ២ដែលជាក្រុមខ្សោយឬ «ហ ជា អ២»។

ហ រក្សាមូលភេទរបស់ខ្លួនដដែល គឺមូលភេទ អ។

ដូចនេះ រ (ព្យាង្គ អ៊) + ហក់ (ព្យាង្គ អ) > រហក់ (ព្យាង្គ អ៊ / ព្យាង្គ អ)។

ទំរង់៖ [ព១ស] + [ព១សព៣] > [ព១ស / ព៤សព៦]

រូបមន្ត៖ [ព១ស] + [ព១សព៣] > [ព១ស / ព៤សព៦]

ព១ ជា អ៊២ ព១ ជា អ២

ព្យាង្គ អ៊ + ព្យាង្គ អ > ព្យាង្គ អ៊ / ព្យាង្គ អ

ក្នុងទីនេះ ព១ ពុំមានឥទ្ធិពលនាំ ព៤ អោយប្តូរមូលភេទជាពួក អ៊ បានឡើយ។

ក្បួន៖ ក្នុងពាក្យពីរព្យាង្គ កាលណាព្យាង្គ អ៊ ខាងដើមកើតមកពីសញ្ញាព្យញ្ជនៈ អ៊២ ព្យាង្គ អ ខាងមុខដែលកើតមកពីសញ្ញាព្យញ្ជនៈ អ២(ហ) ពុំប្រែប្រួលឡើយ គឺថា ព១ និងព៤ ជាអ្នកកំនត់សូរស្រៈក្នុងព្យាង្គរៀងខ្លួន។

ខ.៥.ក្បួនទី៥

ឧទាហរណ៍៖ យីថោ យីកេ យីអើ យោបល់ យោបំ រកម រខាក របស់ រំកាច់ រំដេង លំចង់...។

វិភាគពាក្យ យីថោ៖ យ ជាពួក អ៊ ក្នុងក្រុម២ដែលជាក្រុមខ្សោយឬ «យ ជា អ៊២»។

ថ ជាពួក អ ក្នុងក្រុម១ដែលជាក្រុមខ្លាំងឬ «ថ ជា អ១»។

ថ រក្សាមូលភេទរបស់ខ្លួនដដែល គឺមូលភេទ អ។

ដូចនេះ យី (ព្យាង្គ អ៊) + ថោ (ព្យាង្គ អ) > យីថោ (ព្យាង្គ អ៊ / ព្យាង្គ អ)។

ទំរង់៖ [ព១ស] + [ព១ស] > [ព១ស / ព៤ស]

រូបមន្ត៖ [ព១ស] + [ព១ស] > [ព១ស / ព៤ស]

ព១ ជាអ៊២ ព១ ជា អ១

ព្យាង្គ អ៊ + ព្យាង្គ អ > ព្យាង្គ អ៊ / ព្យាង្គ អ

ក្នុងទីនេះ ព១ ពុំមានឥទ្ធិពលនាំ ព៤ អោយប្តូរមូលភេទជាពួក អ៊ បានឡើយ។

ក្បួន៖ ក្នុងពាក្យពីរព្យាង្គ កាលណាព្យាង្គ អ៊ ខាងដើមកើតមកពីសញ្ញាព្យញ្ជនៈ អ៊២ ព្យាង្គ អ ខាងចុងដែលកើតមកពីសញ្ញាព្យញ្ជនៈ អ១ ពុំប្រែប្រួលឡើយ គឺថា ព១ និងព៤ ជាអ្នកកំនត់សូរស្រៈក្នុងព្យាង្គរៀងខ្លួន។

មូលភេទ អ-អ៊ មិនគ្រាន់តែជាអ្នកចែកស្រៈ ព្យញ្ជនៈ និងព្យាង្គ ជាពីរពួកប៉ុននោះទេ តែមូលភេទនេះនាំឱ្យមានក្បួនប្រាប់ស្រៈ ៩ យ៉ាងថែមទៀតផង។

លោក **សូ មុយឃឿង**

# ការដោះស្រាយចំណោទ (ត)

<u>ជំណាក់ទី២:</u> ការស្រាវជ្រាវរបស់សិស្ស

- គ្រូរៀបចំសិស្សជាក្រុម ២នាក់ៗ
- ឱ្យសិស្សរកវិធីផ្សេងៗដែលអាចដោះស្រាយចំណោទនេះបាន
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សដោះស្រាយ
- គ្រូដើរពិនិត្យមើលការងាររបស់សិស្ស។ បើមានសិស្សមិនទាន់យល់ច្បាស់ គ្រូត្រូវបញ្ឈប់ការងារគេសិន ហើយឱ្យអានចំណោទឡើងវិញដោយប្រុងប្រយ័ត្ន ឬយកសំណួរទាំងពីរខាងលើមកចោទសួរឡើងវិញ លុះត្រាតែគេបានយល់ច្បាស់ល្អ។ បន្ទាប់មកគ្រូត្រូវទុកពេលឱ្យគេធ្វើការងារជាបន្តទៅទៀត។

**គ្រូណែនាំ**

ចូរផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់នូវវិធីដែលអ្នកបានរកឃើញ បើមិនសមស្រប អ្នកអាចកែ អាចលុប និងអាចរកតាមវិធីផ្សេងទៀតបាន។

<u>ជំណាក់ទី៣:</u> ការបូកសរុប

- ឱ្យសិស្សម្នាក់មកបង្ហាញរបៀបរកឃើញចម្លើយដោយធ្វើអំណះអំណាងបញ្ជាក់ផង
- ឱ្យសិស្សដទៃទៀតផ្ទៀងផ្ទាត់ និងកែតម្រូវ ដោយធ្វើអំណះអំណាងផង
- គ្រូសួរទៅក្រុមដទៃទៀតថា បើមានក្រុមណារកឃើញរបៀបរកផ្សេងៗទៀតនោះត្រូវឱ្យពួកគេឡើងមកបង្ហាញពីរបៀបរកនោះដោយធ្វើការអះអាងបញ្ជាក់ផង
- ឱ្យសិស្សឯទៀតផ្ទៀងផ្ទាត់ និងកែតម្រូវ
- ឱ្យសិស្សប្រៀបធៀបរបៀបដោះស្រាយដែលសិស្សរកឃើញផ្សេងៗគ្នា ដើម្បីជ្រើសរើសយករបៀបមួយណាដែលងាយ ដែលរហ័ស និងមានប្រសិទ្ធភាព។

<u>ជំណាក់ទី៤:</u> សន្និដ្ឋាន

- គ្រូសួរៈ

«ដើម្បីអាចដោះស្រាយចំណោទនេះបាន តើគេត្រូវធ្វើដូចម្ដេច?» (គេត្រូវអានអត្ថបទ និងគំនូសតាង (បើមាន) ដើម្បីរកព័ត៌មានដែលមានប្រយោជន៍)

- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់
- គ្រូដឹកនាំធ្វើសំយោគ រួចបង្ហាញអត្ថបទ «គួរចងចាំ»។

| **គួរចងចាំ** |
|---|
| ព័ត៌មានទាំងឡាយដែលគេត្រូវការដើម្បីដោះស្រាយចំណោទ អាចមាននៅក្នុងតារាង ក្នុងគំនូសតាង...។ល។ ដែលតាងឱ្យស្ថានភាពចំណោទមួយ។ |

- ឱ្យសិស្សកត់អត្ថបទ «គួរចងចាំ» ដាក់ក្នុងសៀវភៅ។

**IV-ចម្លើយ**

១-ចំនួនឥដ្ឋការ៉ូរាងចតុកោណកែង

15 x 5 = 75ការ៉ូ

២-ចំនួនឥដ្ឋការ៉ូរាងការេ

10 x 10 = 100ការ៉ូ

៣-តម្លៃឥដ្ឋការ៉ូរាងចតុកោណកែង

6000៛ x 75 = 450000៛

៤-តម្លៃឥដ្ឋការ៉ូរាងការេ

4000៛ x 100 = 400000៛

៥-ប្រាក់ចំណាយសរុបរបស់នាយកសាលា

450000៛ + 400000៛ = 850000៛

៦-ប្រវែងបណ្តោយបណ្ណាល័យ

50 x 15 = 750សម

៧-ប្រវែងទទឹងបណ្ណាល័យ

80 x 5 = 400សម

៨-ប្រវែងជ្រុងទីចាត់ការ

50 x 10 = 500សម

## V-**កំណត់សម្គាល់**

គេអាចធ្វើសកម្មភាពដូចគ្នា ចំពោះគ្រប់រូបភាពគំនូសតាង។ នៅទីបញ្ចប់ គោលបំណងនៃការងារនេះ គឺនាំសិស្សដែលត្រូវការជាចាំបាច់នូវគំនូសតាងឱ្យគេមានសមត្ថភាពគូរគំនូសនោះដែលនឹងអាចជួយពួកគេក្នុងការដោះស្រាយចំណោទបាន។

ដូច្នេះ គ្រូត្រូវឱ្យសិស្សធ្វើជាបុគ្គលនូវចំណោទខាងក្រោមនេះនៅក្នុងថ្នាក់រៀន។

<u>ចំណោទ</u>

១/




ក)តើផ្លូវណាដែលខ្លីជាងគេ ដើម្បីធ្វើដំណើរពីភូមិ ក ទៅភូមិ ឃ?

ខ)ចូរបំពេញតារាងខាងក្រោម ដោយចម្ងាយផ្លូវពីភូមិមួយទៅភូមិមួយ ដោយជ្រើសរើសយកតែចម្ងាយផ្លូវណាដែលជិតជាងគេ?

| | ក | ខ | គ | ឃ | ង |
|---|---|---|---|---|---|
| ក | | 2,8 | | | |
| ខ | | | | | |
| គ | | | | | |
| ឃ | | | | | |
| ង | | | | | |

**<u>ចំណោទ</u>**

២/




ផ្ទះសំណាងស្ថិតនៅកាច់ជ្រុងផ្លូវលេខ១០៣ និង៣០០ (ត្រង់ចំណុច ក)។ ដើម្បីធ្វើដំណើរទៅវិទ្យាល័យព្រះយុគន្ធរ សំណាងត្រូវធ្វើដំណើរតាមផ្លូវលេខ១០៣, ២៨៨ និងមហាវិថីព្រះមុនីវង្ស។

ចូររកចម្ងាយផ្លូវដែលសំណាងត្រូវធ្វើដំណើរ។

ដកស្រង់ដោយលោកស្រី **ប៊ុន សារ៉ន**

«អ្នកដែលចង់រៀន ទោះនៅដល់ទីណា ក៏មានគ្រូដែរ។»

**ពុទ្ធសុភាសិត**

# ឪពុកម្តាយសិស្ស និងគ្រូបង្រៀនត្រូវ ប្រាស្រ័យទាក់ទងគ្នា

-ជនខ្លះយល់ថា៖

ឪពុកម្តាយមានភារកិច្ចតែត្រឹមចិញ្ចឹមថែរក្សាបុត្រធីតា ចំណែកការអប់រំកុមារឱ្យបានជាមនុស្សចេះធ្វើការរកស៊ី ចេះរស់នៅក្នុងសង្គម មានចរិយាល្អ នោះជាបន្ទុកនៃគ្រូបង្រៀន ព្រោះគ្រូជាអ្នកមានចំណេះវិជ្ជាជ្រៅជ្រះផង មានវិជ្ជាខាងគរុកោសល្យ និងចិត្តសាស្ត្រ ជាមធ្យោបាយសម្រាប់ផ្ទេរចំណេះគ្រប់យ៉ាងមកឱ្យសិស្សបានដោយងាយផង។ ន័យមួយទៀត ប្រាក់បំណាច់ក៏រាជការបានចេញឱ្យគ្រូបង្រៀនរៀងរាល់ខែគួនល្មមហើយ ឯសិស្សរៀនពូកែ ឬមិនពូកែស្រេចលើគ្រូ។ លោកគ្រូអ្នកគ្រូនឹងដោះសាថា ទាស់ពីនេះ ឬទាស់ពីនោះយករួចខ្លួនមិនខាន។ ការយល់បែបនេះនឹងទុកជាខុសក៏ពុំបាន នឹងទុកថាត្រូវក៏ពុំបានទៀត តែយើងអាចវិនិច្ឆ័យ ឪពុកម្តាយដូចពោលខាងលើនេះថា ជាមនុស្សពាយងាយចំពោះការអប់រំកូន គិតតែចង់រលាស់ចោលនូវករណីយកិច្ចដែលខ្លួនត្រូវទទួលខុសត្រូវលើវាសនាកូនទៅអនាគត។

អ្នកផងជ្រាបហើយថា អ្នកដែលមានឧត្តមគតិស្របគ្នា ឱ្យសិស្សបានចំរើនខាងកាយ ខាងបញ្ញា និងខាងចរិយា នោះមានតែគ្រូបង្រៀន និងឪពុកម្តាយសិស្សទេ។ បំណងឪពុកម្តាយចង់ឱ្យបុត្រធីតាល្អត្រកាលប៉ុណ្ណា បំណងគ្រូក៏ប៉ុណ្ណោះដូចគ្នា។ បើគោលបំណងមានតែមួយដូចគ្នាយ៉ាងនេះហើយ ហេតុម្តេចក៏ម្នាក់ៗចង់ទម្លាក់ទោសទៅលើម្នាក់ៗតាមតែនឹកឃើញ ម្តេចក៏លោកគ្រូអ្នកគ្រូ និងមាតាបិតាសិស្ស មិនចាប់ដៃគ្នាខំអប់រំសិស្សទៅ។

យើងបានសង្កេតឃើញ ឪពុកម្តាយ និងលោកគ្រូអ្នកគ្រូភាគច្រើន សំខាន់នៅទីក្រុងមិនទាំងស្គាល់គ្នាផង ឪពុកម្តាយខ្លះស្គាល់សាលារៀនតែថ្ងៃដំបូង ដែលនាំកូនទៅប្រគល់ឱ្យនាយកសាលា កូនបានចូលរៀនហើយក៏ហើយទៅ ឥតមានអើពើរវល់សួរលោកគ្រូអ្នកគ្រូពីគំនិត ចិត្ត ពីកិច្ចរៀនសូត្ររបស់កូនឡើយ មិនតែប៉ុណ្ណោះ ថែមទាំងមិនសរសេរជំរាបគ្រូបង្រៀនពីការខ្ជិលឬឧស្សាហ៍របស់កូននៅក្នុងតារាងលទ្ធផល (សៀវភៅតាមដាន) ប្រចាំខែរបស់សិស្ស ក្នុងសៀវភៅដែលលោកនាយក និងគ្រូបង្រៀនប្រចាំថ្នាក់ផ្ញើមកខ្លួនជាដំណឹងផង។ ចំណែកគ្រូបង្រៀនខ្លះវិញ ក៏គ្មានឆ្លៀតពេលមកទាក់ទងនឹងឪពុកម្តាយសិស្សដែរ។ អ្នកអប់រំទាំងនេះ រស់នៅដាច់ដោយឡែកពីគ្នា តាំងពីយូរកាលមកហើយ។ តាមការពិសោធ និងគន់គិតទៅឃើញថាហាក់ដូចជាមានអ្វីមួយមកកាត់ ឬឃាំងមិនឱ្យអ្នកអប់រំទាំងនេះទាក់ទងគ្នា មានន័យថា ឪពុកម្តាយសិស្សញញើតសាលា សាលាញញើតផ្ទះឪពុកម្តាយសិស្ស។

តាមការអប់រំទំនើប មាតាបិតាសិស្សនិងគ្រូ ត្រូវមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ ទើបការអប់រំសិស្សបានល្អប្រពៃ។ តើក្នុងមួយថ្ងៃៗសិស្សនៅសាលាប៉ុន្មានម៉ោង? ពេលសិស្សនៅសាលា ឪពុកម្តាយដឹងទេថា កូនខ្លួនយកចិត្តទុកដាក់ក្នុងការរៀនសូត្រឬទេ? ដឹងអាចារៈគំនិតមារយាទកូនយ៉ាងដូចម្តេចដែរ? ពេលកូននៅផ្ទះវិញ គ្រូបង្រៀនក៏មិនបានដឹងថា សិស្សខ្លួនមានអាចារៈ និងចរិយាយ៉ាងណាៗនោះដែរ។

បើមិនស្គាល់ក្មេងប្រាកដ ធ្វើម្តេចឡើយអ្នកអប់រំនឹងអប់រំសិស្សកើត ឬមួយក៏ចេះតែបង្ហាត់បង្រៀនសិស្សឬកូនព្រាវៗទៅ។

គ្រូពេទ្យព្យាបាល នឹងមើលជំងឺមួយជារហ័ស លុះណាតែស្គាល់ជំងឺនោះច្បាស់។ មុននឹងចាក់ថ្នាំ មុននឹងឱ្យថ្នាំអ្នកជំងឺលេប គប្បីគ្រូពេទ្យពិនិត្យ អង្កេត សួរៈ ឱ្យស្គាល់ច្បាស់នូវជំងឺ ជំងឺនេះមានកំណើតមកពីណា បណ្តាលមកអំពីអ្វី មានលក្ខណៈដូចម្តេច ជំងឺនេះនឹងទៅជាយ៉ាងណាសិន ទើបអាចដាក់ថ្នាំមើលទៅដល់ ឆាប់ជាបាន។

យ៉ាងណាមិញគ្រូក៏យ៉ាងនោះដែរ ដំបូងលោកគ្រូអ្នកគ្រូ និងឪពុកម្តាយត្រូវស្គាល់ចិត្ត គំនិត អាចារៈសិស្ស ព្រោះថាការដែលសិស្សរាខ្ជិលក្តី ឧស្សាហ៍ក្តី មិនព្រមរៀនក្តី ព្រមរៀនក្តី រៀនមិនចេះចាំក្តី មានកិរិយាអាក្រក់ក្តី សុទ្ធតែមានហេតុទាំងអស់ ហេតុទាំងនេះមានលេចឱ្យឃើញនៅសាលាផង នៅផ្ទះផង។ ការប្រមូលហេតុទាំងនេះអាចឱ្យយើងសន្មតថាជាជំងឺប្រចាំកាយរបស់សិស្សក្នុងការសិក្សានោះ។ បើគ្មានការសន្ទនារវាងអ្នកអប់រំទាំងនេះទេ នោះមានន័យថា មិនទាន់ស្គាល់សិស្សជាក់លាក់ឡើយ។ ដរាបណាអ្នកអប់រំមិនទាន់ស្គាល់សិស្សទេ ដរាបនោះ ការអប់រំសិស្សរបស់លោកគ្រូក៏ពុំបានទទួលលទ្ធផលល្អដែរ។

សរុបសេចក្តីទៅ តើត្រូវធ្វើដូចម្តេចដើម្បីឱ្យសាលា និងគ្រួសារមានការទាក់ទងគ្នា!

យើងដឹងច្បាស់ហើយថា នៅកម្ពុជាយើងសព្វថ្ងៃ សាលារៀននិងគ្រួសារមិនគ្រាន់តែខ្វះការរួបរួមឱ្យបានជិតស្និទ្ធនោះទេ ថែមទាំងមានការប្រឆាំងគ្នាខ្លះទៀតផង មានរឿងជាច្រើនបញ្ជាក់យ៉ាងច្បាស់លាស់ថា ដូចជាឪពុកម្តាយសិស្សខ្លះនិយាយទិតៀនពីសាលា និយាយដើមពីគ្រូ ពេលដែលគ្រូយើងខ្លះប្រព្រឹត្តខុសដោយអចេតនាណាមួយនោះ។ រឿងទាំងនេះបានកើតឡើងដោយសារតែគូវិវាទទាំងនោះមិនដឹង ឬភ្លេចនូវករណីយកិច្ចរបស់ខ្លួនចំពោះប្រយោជន៍អនាគតនៃកូនរបស់ខ្លួន។

ដើម្បីបំបាត់ការអកុសលទាំងនេះ នៅក្នុងពេលបវេសនកាលរៀងរាល់ឆ្នាំ នាយកសាលាគប្បីអញ្ជើញឪពុកម្តាយសិស្សរបស់ខ្លួនឱ្យមកប្រជុំនៅសាលារៀន ដើម្បីសន្ទនាគ្នាអំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍របស់កូនដូចបានអធិប្បាយខាងលើនេះ។

នៅឱកាសនេះ នាយកសាលាត្រូវពន្យល់ដល់មាតាបិតាសិស្សថា នាយកសាលានិងគ្រួសារជាកម្លាំងពីរដែលត្រូវរួបរួមគ្នាធ្វើសហប្រតិបត្តិការក្នុងការអប់រំបុត្រធីតានេះឯង។ សាលានិងគ្រួសារជាកម្លាំងពីរខាងផ្នែកអប់រំ កម្លាំងនេះបើបែកគ្នានឹងនាំឱ្យអន់ថយល្បឿនសិក្សា តែបើរួបរួមគ្នាវិញនោះ កម្លាំងទាំងពីរនេះអាចធ្វើសិស្សទៅតាមសេចក្តីត្រូវការនៃមាតាបិតាបានដោយងាយ។

ចប់សន្ទនាហើយ លោកនាយកសាលាគប្បីចាត់គ្រូគ្រប់ថ្នាក់សាកសួរព័ត៌មានពីឪពុកម្តាយសិស្សរៀងៗខ្លួនដូចខាងក្រោមនេះ៖

**ក-សុខភាព** : កូនអ្នកមានសុខភាពល្អឬទេ ពីមុនដែលមានកើតជំងឺអ្វីមួយនាំឱ្យងងឹតភ្នែក ថ្លង់ ខូចសួត ឡើមបេះដូងឬគ្មាន...។

**ខ-បញ្ញាស្មារតី** : កូនអ្នកឆ្លាតខាងអ្វី ចេះធ្វើអ្វីខ្លះ ជាក្មេងនឹងធឹងឬឡឹកឡក់ រហ័សរហួន ឬស្លឹកស្រពន់ ឆ្លាតខាងអ្វីជាងគេ...។

**គ-គំនិតមារយាទ** : កូនអ្នកចេះប្រស្រ័យទាក់ទងនឹងអ្នកដទៃឬទេ ឬក៏ខ្លាចគេ ចេះរំភើបដែរ ឬខុយមុយ ចិត្តវាល្អ ឬគិតតែខ្លួនឯង ខ្ជិលខាងអ្វី មានចំណូលចិត្តអ្វីប្លែកពីគេ ចូលចិត្តសណ្តាប់ធ្នាប់ ចូលចិត្តស្អាត សេចក្តីពិតនិងយុត្តិធម៌ឬទេ មានឆន្ទៈយ៉ាងណា មានទម្លាប់អ្វីមួយ ហើយឈប់វិញបានដោយងាយឬទេ...។

តើអ្នកចង់ឱ្យចរិយាកូនអ្នក មានភាពយ៉ាងណា ឬចង់ឱ្យគេធ្វើអ្វីដល់ពេលគេធំឡើង។

សំណួរទាំងនេះជាមធ្យោបាយសម្រាប់ទាក់ទងឱ្យស្គាល់ឪពុកម្តាយសិស្សផង និងជាមធ្យោបាយសម្រាប់ដឹកនាំសិស្សក្នុងការអប់រំផង។

នៅទីបញ្ចប់ លោកនាយកសាលាគួរបន្ថែមសេចក្តីទៀតថា បើមានអ្វីមិនគប្បីចេញពីកូន ចំពោះការសិក្សានោះ សុំមាតាបិតាប្រញាប់ទៅជួបនឹងលោកនាយកសាលា និងគ្រូប្រចាំថ្នាក់ សាកសួររឿងនោះឱ្យដឹងសព្វគ្រប់ អស់សេចក្តី ដើម្បីបំបាត់ងឿងឆ្ងល់ ដើម្បីរិះរកមធ្យោបាយជួយអប់រំកូនពីក្រៅសាលាឱ្យបានត្រូវផ្លូវល្អផង។ ចំណែកគ្រូបង្រៀនវិញ ក៏គួរឆ្លៀតទៅលេងផ្ទះសិស្ស ធ្វើការទាក់ទងជាមួយមាតាបិតាសិស្សឱ្យបានជិតស្និទ្ធប្រយោជន៍បានស្គាល់របៀបចិញ្ចឹម របៀបគ្រប់គ្រងកូនក្នុងគ្រួសារនីមួយៗដែរ។

សូមឪពុកម្តាយ និងលោកគ្រូ អ្នកគ្រូពួតដៃគ្នាអប់រំសិស្ស ដែលជាជីវិតប្រទេសទៅអនាគតកុំបីមើលបំណាំគ្នាឡើយ៕

លោក **ចែម ធាន**

## ខាសនាអក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែររុងរឿងដោយសារខ្មែរ ពុំហ៊ានបែកបែរឱ្យភ្លាត់ខុស
ជនខ្មែរគ្រប់គ្នាទាំងស្រីប្រុស ពុំហ៊ានបង្ខូសឱ្យខូចបង់។
ជនខ្មែរគ្រប់គ្នាលើកតំកើង ដំឡើងពាក្យពេចន៍ដោយផ្ចិតផ្ចង់
ខ្មែរជាគ្រហស្ថខ្មែរជាសង្ឃ ខំប្រឹងសម្រង់អក្សរជាតិ៕

សម្តេចព្រះសង្ឃរាជ **ជួន ណាត**

# មូលដ្ឋាននៃការអប់រំ

**ឧទ្ទេសនាម**

វិធីសាស្ត្រជាការចាំបាច់ក្នុងការបង្រៀន ការអប់រំត្រូវពឹងផ្អែកទៅលើវិធីសាស្ត្រជាដាច់ខាត ដោយមានសំអាងទៅលើ ២ សំខាន់ពីរយ៉ាងគឺ៖

១-ការអប់រំជាភារៈលំបាក

២-ការអប់រំត្រូវទទួលខុសត្រូវយ៉ាងធ្ងន់

បើអ្នកអប់រំទាំងឡាយទទួលស្គាល់នូវ ២ សំខាន់ពីរនេះហើយ បញ្ហាធំមួយទៀតដែលផុសចេញភ្លាមៗអំពីការអប់រំនោះគឺ «តើការអប់រំត្រូវបិតនៅលើមូលដ្ឋានណា? ហើយតើអ្នកអប់រំត្រូវយល់ និងបកស្រាយទ្រឹស្ដីនៃការអប់រំយ៉ាងដូចម្ដេចខ្លះ?»

ខ្ញុំសូមមិត្តអ្នកអប់រំទាំងឡាយអនុញ្ញាតឱ្យខ្ញុំលើកយកបញ្ហាថ្មីនេះ មកធ្វើអត្ថាធិប្បាយដោយសង្ខេបជាគោលៗក្នុងអត្ថបទនេះ មុននឹងសរសេរអត្ថបទឯទៀតដែលទាក់ទងនឹងវិធីសាស្ត្រ ដោយហេតុថា វិធីសាស្ត្រជាមធ្យោបាយដែលប្រឌិតបង្កើតចេញអំពីគោលការណ៍នៃការអប់រំតែម្ដង។

**១-តើអ្វីខ្លះដែលជាមូលដ្ឋាននៃការអប់រំ?**

ដើម្បីឆ្លើយតបបញ្ហានេះ យើងត្រូវស្គាល់ទ្រឹស្ដីផ្សេងៗដែលមានមកពីពេលមុនៗ។

ក្នុងរយៈពេល ៩៥ឆ្នាំកន្លងទៅ រហូតមកទល់បច្ចុប្បន្នកាលនេះ អ្នកគរុសាស្ត្របានធ្វើការស្រាវជ្រាវរកគោលការណ៍អប់រំឱ្យបានពិតប្រាកដរឹងប៉ឹង ដើម្បីជាបង្អែក និងជាពន្លឺនៃអ្នកអប់រំផង ហើយដើម្បីប្រឌិតវិធីសាស្ត្រឱ្យមានប្រសិទ្ធភាពផង។ ក្នុងការស្រាវជ្រាវនេះ មានយោបល់ជាច្រើនផុសចេញលេចឡើង យោបល់ខ្លះក៏ស្របគ្នា យោបល់ខ្លះក៏ខ្វែងគ្នា ពុំចុះសម្រុងគ្នា យោបល់ខ្លះទៀតផ្ទុយគ្នាស្រឡះ។

អ្នកខ្លះយល់ថា គួរតែយកអង្គមនុស្សជាមូលដ្ឋានធំបំផុត គឺអប់រំយ៉ាងណាឱ្យបុគ្គលនីមួយៗទៅជា «មនុស្សឧត្តម» ព្រោះគេទុកចិត្តលើសមត្ថភាព និងលទ្ធភាពនៃមនុស្ស គំនិតដែលលើកតំកើងមនុស្សបែបនេះ គេឱ្យឈ្មោះថា «មនុស្សនិយម»។

អ្នកខ្លះយល់ថា គ្មានមធ្យោបាយអ្វីល្អប្រសើរជាងវិទ្យាសាស្ត្រទេ ដើម្បីអប់រំមនុស្សឱ្យបានល្អគ្រប់វិស័យ ព្រោះវិទ្យាសាស្ត្រនេះហើយដែលបង្រៀនមនុស្សឱ្យចេះគិតពិចារណាត្រឹមត្រូវ ចេះវិនិច្ឆ័យទៅតាមការពិត។ កាលណាមនុស្សស្គាល់ធម្មជាតិ ស្គាល់ខ្លួនឯង ស្គាល់ព្រឹត្តិការណ៍ក្នុងលោក ស្គាល់ច្បាប់ទាំងឡាយដែលមានទំនាក់ទំនងរវាងវត្ថុនានា គឺសរុបឱ្យខ្លីទៅ កាលណាមនុស្សស្គាល់ការពិត ដែលវិទ្យាសាស្ត្របានរកឃើញ ឬបានបញ្ជាក់ហើយនោះ មនុស្សអាចមានសមត្ថភាពនឹងយិតយោងខ្លួនឯងបានគ្រប់វិស័យ ហើយអាចប្រែក្លាយទៅជាមនុស្សស្គាល់ខុសត្រូវ ល្អអាក្រក់ មានសីលធម៌ក្នុងខ្លួនព្រមទាំងទៅជាពលរដ្ឋមានតម្លៃ អាចបំរើសង្គម លើកឋានៈសង្គមបានដូចបំណង។ ទ្រឹស្ដីដែលយកវិទ្យាសាស្ត្រជាមូលដ្ឋានបែបនេះ គេឱ្យឈ្មោះថា វិទ្យាសាស្ត្រនិយម។

អ្នកខ្លះនិយមធម្មជាតិជាមូលដ្ឋាននៃការអប់រំ ព្រោះគេយល់ថា មានតែធម្មជាតិទេទើបផ្ដល់ការពិសោធ ឬចំណេះផ្សេងៗបាន ធម្មជាតិនេះជាក្រាំងធំដែលមនុស្សអាចទាញយកវិជ្ជាគ្រប់បែបយ៉ាង។ ឯសង្គមទេដែលធ្វើឱ្យមនុស្សអាក្រក់ ធ្វើឱ្យមនុស្សបាត់សេរីភាព ធ្វើឱ្យមនុស្សគ្មានសីលធម៌។ លោក ហ្សង់ ហ្សាក់រូស្សូ បានពោលថា «មនុស្សកើតឡើងល្អ ប៉ុន្តែសង្គមទេដែលធ្វើឱ្យមនុស្សពុករលួយ»។

អ្នកខ្លះទៀតយល់ថា ត្រូវយកសង្គមជាធំវិញ ព្រោះមនុស្សរស់នៅក្នុងសង្គម។ មនុស្សជាធាតុមួយនៃសង្គម ឬ

ជាសមាជិកនៃសង្គម។ សង្គមជាមជ្ឈដ្ឋាននៃបុគ្គល ដូចទឹកជាមជ្ឈដ្ឋាននៃត្រី ជោគវាសនារបស់មនុស្សរមែងតែងតែជាប់ទាក់ទងយ៉ាងជិតស្និទ្ធនឹងសង្គម ជីវភាព សុភមង្គលសេចក្ដីថ្លៃថ្នូររបស់បុគ្គលក៏ផ្លាស់ប្ដូរទៅតាមសង្គមដែរ។ បុគ្គលត្រូវការរស់នៅជាបាច់ ជាចង្កោម ដើម្បីការពារ ឬកសាងប្រយោជន៍ខ្លួន។ អ្វីដែលម្នាក់ៗធ្វើពុំកើត គេអាចធ្វើឡើងបានដោយរួមគ្នា។ ដូច្នេះហើយបានជាសង្គមវិទូមានគំនិតថា សាលារៀនកសាងឡើងដោយសារសង្គម ដើម្បីសង្គម ឬ «ការអប់រំត្រូវធ្វើឱ្យបុគ្គលក្លាយទៅជាមនុស្សដែលសង្គមត្រូវការ» ឬ «ការអប់រំត្រូវធ្វើឡើងក្នុងសង្គម ដើម្បីសង្គម»។

ទ្រឹស្ដីចំពោះឧត្តមគតិនៃការអប់រំ នៅមានច្រើនទៅទៀតដែលយើងពុំអាចយកមកពណ៌នាបានសព្វគ្រប់ឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យោបល់អ្នកគរុកោសល្យចំពោះការអប់រំ ចេះតែមានការប្រែប្រួលទៅតាមកាលៈទេសៈ ឬទៅតាមហេតុការណ៍ផ្សេងៗ។ មតិទាំងនោះមានល្អ មានអាក្រក់ មានខុស មានត្រូវ ឬមានការខ្វះខាតចំណុចនេះ ឬចំណុចនោះ។

អាស្រ័យហេតុនេះ តើយើងត្រូវពឹងផ្អែកទៅលើគោលការណ៍ណាមួយទើបចាត់ថា ត្រឹមត្រូវ?

(នៅមានត)

ដកស្រង់ដោយលោក **ចែម ធាន**

---

## កូនកុំ...

កូនកុំ គិតខ្លីជឿមិត្តភក្ដិ នាំកូនឱ្យធ្លាក់ផ្លូវអបាយ
កូនកុំ តាមគេចោលពុកម្ដាយ កូនគិតវែងឆ្ងាយណាកូនណា។

កូនកុំ ធុញទ្រាន់សម្ដីឪ ម៉ែណែនាំផ្លូវៗសុខា
កូនកុំ ភ្លេចគ្រូៗបាធ្យាយ បង្រៀនកូនថាកូនសិស្សល្អ។

កូនកុំ ភ្លេចប្រាណជាមនុស្ស កូនគិតឱ្យលុះខ្ពស់បវរ
កូនកុំ ធ្វើជាតិខ្លួនឱ្យក្រ កូនត្រូវបន្តស្នងកិច្ចការ។

កូនកុំ ភ្លេចភ្នាំងស្មារតី ខ្មែរមានឈ្មោះល្បីៗអស្ចារ្យ
កូនកុំ បណ្ដោយឱ្យអាត្មា បង្ខូចកេរតាយាយសារកូន។៚

**ហាម ទ្រា**




# ប្រាសាទព្រះវិហារខ្មែរ ជាបេតិកភ័ណ្ឌពិភពលោក

(បទពាក្យ ៧)

១. ភ្លៀងផ្គររន្ទះគ្រហឹមថ្ងូរ ព្យុះបោកបន្ទរសូរគគ្រឹក
កក្រើកញ័រដីព្រៃភ្នំទឹក ជាស់ក្រើនរំលឹកខ្មែរគ្រប់ប្រាណ។

២. ឱ្យរួមដៃគ្នារក្សាថៃ អរិយធម៌ខ្មែរពីបុរាណ
ស្ថាបត្យកម្មល្អថ្កើងថ្កាន វិចិត្រហួសស្មានលើលោកីយ៍។

៣. ថ្ងៃទីប្រាំពីរខែកក្កដា ជោគជ័យអស្ចារ្យសូន្យប្រាំបី[១]
គេបិទកាណាជាចារស្ដី ប្រាសាទខ្មែរល្បីចុះបញ្ជី។

៤. បេតិកភ័ណ្ឌពិភពលោក ជាតិសាសន៍គគោកគ្រប់ទិសទី
នៅយូណេស្កូឈ្នះទីពីរ[២] សាក្សីមូលមីរជួយពិនិត្យ។

៥. ប្រាសាទព្រះវិហារជាំក្សាន្ត អង្គក្សត្រខ្មែរសាងដោយប្រាជ្ញពិត
លើកំពូលភ្នំប្រាង្គប្រណីត ទីឋានសក្តិសិទ្ធិសក្ការៈ។

៦. ប្លង់ប្រាសាទនេះប្រសើរក្រៃ សាងឡើងដោយដៃច្រើនជាន់ថ្នាក់
ផ្ទាំងថ្មធំតូចអួសសែងដាក់ ផុសខាត់ជាប់ឆ្លាក់មិនប្រហែស។

៧. ក្បាច់ផ្កាភ្ញីវល្លិអប្សរា នាគគ្រុឌគោខ្លាដំរីសេះ
តាមផ្ទៃជញ្ជាំងឃ្លាំងចំណោះ ផ្តល់ជាពិសេសជនគ្រប់គ្នា។

៨. នាគក្បាលប្រាំពីរនៅយាមផ្លូវ គោចាស់ពោមស្លូវចាំច្រកទ្វារ
យក្សហនុមានជួយការពារ នាគម្ករអោចាំប្រហារ។

៩. សូមនឹកដល់ម្ចាស់ទឹកម្ចាស់ដី ម្ចាស់ថ្មម្ចាស់ព្រៃនិងអ្នកតា
សិក្ខាស្វារៈ[៣] ឫទ្ធិអស្ចារ្យ ឥន្ទ្រព្រហ្មទេវតារក្សាថៃ។

១០. ឱ្យមានតែសុខ និងសេរី នៅក្នុងដែនដីសីមាខ្មែរ
សង្ឃរាស្ត្ររាជការចម្ការស្រែ ឱ្យបានជួបតែសុខចម្រើន៕

លោក **ឡូប ហុកសេង**

(១)សូន្យប្រាំបី មានន័យថា ឆ្នាំពីរពាន់ប្រាំបី (២០០៨)។ (២)ឈ្នះទី១: ជាជ័យជំនះឆ្នាំ១៩៦២, ឈ្នះទី២: ចូលជាបេតិកភ័ណ្ឌពិភពលោកឆ្នាំ២០០៨
(៣)សិក្ខាស្វារៈ៖ ជាព្រះអាទិទេពដែលមានឫទ្ធានុភាពខ្លាំងក្លានៅតំបន់ប្រាសាទព្រះវិហារ។

# ម្តាយ និងកូនរួមគ្នាអភិវឌ្ឍសង្គម

(បទពាក្យ ៧)

១. កូនជាទំពាំងស្នងឫស្សី ស្នងគ្រប់អ្វីៗបន្សល់ទុក
តពីតំណម្តាយឪពុក បានបន្សល់ទុកកន្លងមក។
២. ឪពុកអ្នកម្តាយជំនាន់មុន ខំប្រឹងរែកពុនខំរិះរក
កសាងស្នាដៃកន្លងមក ដល់កូនពន្លកជំនាន់ថ្មី។
៣. ស្រទាប់យុវវ័យជំនាន់ក្រោយ កូនកុំកន្តើយខំឃ្មាតខ្មី
រួបរួមសាមគ្គីគ្រប់អ្វីៗ រួមគ្នាពូតដៃកសាងជាតិ។
៤. នារីជាម្តាយជាអ្នកគ្រូ លៃលកគិតគូរមិនឲ្យឃ្លាត
អប់រំណែនាំបន្ថែមទៀត ឲ្យកូនជួយជាតិទាំងអស់គ្នា។
៥. កូនរួមសហការជាមួយម្តាយ កូនអើយត្រូវស្តាយពេលវេលា
ជួយការងារម្តាយទាំងអស់គ្នា ដើរតាមមាគ៌ាអភិវឌ្ឍន៍។
៦. សង្គមបច្ចុប្បន្នត្រូវការកូន ត្រូវការមោសស្ទួនយ៉ាងទៀងទាត់
កម្លាំងយុវវ័យពិតប្រាកដ ជួយអភិវឌ្ឍក្នុងសង្គម។
៧. ម្តាយសូមផ្តែផ្តាំឲ្យកូនស្ងួន ចូរកូនថែជួនខ្លួនមាសម៉ុម
កុំឲ្យធ្លាក់ក្នុងភាពមិនសម ល្បែងក្នុងសង្គមដែលពាលា។
៨. សង្គមជឿនលឿននាបច្ចុប្បន្ន ទាំងល្អឧត្តមទាំងបញ្ហា
ជីវិតរស់នៅជួបពើតផ្សា ថ្នាំញៀននានាដែលមិនល្អ។
៩. កូនជៀសឲ្យផុតទុក្ខទាំងឡាយ រស់គិតវែងឆ្ងាយមានសីលធម៌
ចូរកូនដើរតាមផ្លូវបវរ ចូរកុំបង្កភាពទុក្ខភ័យ។
១០. ព្រោះកូននេះហើយសសរស្តម្ភ យុវវ័យឧត្តមដ៏ឈ្លាសវៃ
ប្តេជ្ញាការពារបៀងរាល់ថ្ងៃ ការពារបុរីដែនខេមរា។
១១. សង្គមពេញដោយធនធានមនុស្ស កូនស្រីកូនប្រុសមានប្រាជ្ញា
អាចជួយកសាងជាតិខេមរា ជីវិតភ្លឺថ្លាខ្ពស់រុងរឿង។
១២. ជាតិឈានទៅមុខដោយសារយើង ជាតិថ្កុំជាតិថ្កើងដោយសារកូន
សាមគ្គីរួមគ្នាមិនសាបសូន្យ ព្រះធម៌ជាក្បួនជួយឃុំគ្រង។

លោកជំទាវ ហង់ ភារី អ៊ុម សិទ្ធី

# អនិច្ចាផ្កាសាកល

(លំនាំបទកាកគតិ)

គួរឱ្យអនិច្ចា ស្រស់ក្លិនបុប្ផា បុប្ផាសាកល
ត្រូវខ្ទាំខ្ទេចខ្ទី ខ្ទេចខ្ទីគ្មានសល់ បាក់មែកតាមខ្យល់
គល់ទៅទាំងដើម។

កាលមុនបុប្ផា រីកស្រស់អស្ចារ្យ ពេលត្រូវសន្សើម
ផ្ការីកស្គុសស្គាយ ពេលព្រឹកចាប់ផ្ដើម ល្អស្រស់សម្បើម
គួរឱ្យចាប់ចិត្ត។

ឥឡូវបុប្ផា ត្រូវគេប្រហារ ឱ្យស្រពោនស្វិត
ប្រែប្រួលធាតុដើម ដែលជាមជាប់ជិត ស្រពោនព្រោះត្បិត
សន្សើមឥតផ្កា។

តើមកពីអ្វី? ឱ្យផ្កាស្រស់ស្រី អប្រិយឥតការ
ឬមកពីដើម ជាអ្នកប្រហារ ឱ្យឆាយច្រើនសា
ផ្កាអស់តម្លៃ។

ឬមកពីអ្នក មានជំនឿជាក់ វប្បធម៌សម័យ
យកមកដាក់ខ្លួន អួតឫកក្រាស់ក្រៃ លូកមាត់ប៉ះដៃ
វាយឫកឥតក្រែង។

ថាខ្លួនជាផ្កា ដែលស្រស់សង្ហា ល្អពិតជាក់ស្ដែង
ភ្លើតភ្លើនភ្លេចខ្លួន ហាក់ចូលក្នុងល្បែង កន្លង់ប្រឡែង
ព្រុបយ៉ាងសប្បាយ។

ពេលខ្លួនទៅហើយ គេមិនកន្ដើយ ជួយធ្វើឧបាយ
ទាក់ទាញមិត្តខ្លួន ឱ្យខំប្រែក្លាយ លាយពណ៌ជាល្បាយ
ក្នុងហ្វូងកន្លង់។

នេះផ្កាសម័យ ភ្លេចអស់តម្លៃ ទៅចោលបោះបង់
ថាខ្លួនគ្រាន់បើ ធ្វើតាមចំណង់ បោះចោលសំណង់
មួយក្នុងជីវិត។

សូមផ្កាទាំងឡាយ អ្នកកុំសប្បាយ ភ្លេចពីការពិត
ថាខ្លួនផ្កាខ្មែរ ស្លៀកពាក់ជុំជិត ត្រូវមានគំនិត
ចេះរក្សាផង។

ហើយត្រូវអាណិត សាកលមានចិត្ត ក្នុងគោលបំណង
ចង់ឱ្យកូនខ្មែរ ចេះព័ទ្ធរបង ហើយប្រាថ្នាប៉ង
លើកស្ទួយវប្បធម៌។

លោក **យុង គឹមហ៊ាន**
មន្ត្រីនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រះវិហារ

# ក្រុងថ្មីនៃកម្ពុជា

(លំនាំបទពាក្យប្រាំបី)

១- ខេត្តកំពង់ចាមកើតក្រុងថ្មីពីរ
និងកំពង់ចាមសែនសមសោភា
គឺសួងរមណីយសែនល្អអស្ចារ្យ
ទីតាំងមូលមីរជនាច្រើនល្បាយ។

២- ស្វាយរៀងក៏មានក្រុងថ្មីពីរដែរ
ប្រជាសុខុមរស់ជុំសប្បាយ
បាវិតស្និទ្ធស្នេហ៍និងស្វាយរៀងអាយ
ព្រំដែននាយខេត្តខ័ណ្ឌសីមា។

៣- បន្ទាយមានជ័យបន្ថែមសម្បស្ស
គឺក្រុងប៉ោយប៉ែតគួរឱ្យចេតនា
ក្រុងថ្មីល្បីឈ្មោះសព្វអស់ជនា
មួយទៀតនាមថាសិរីសោភ័ណ។

៤- ខេត្តកំពង់ឆ្នាំងល្បីខាងស្មូនដី
ក្រុងកំពង់ឆ្នាំងថ្មីថ្កោងឮលាន់
កើតក្រុងមួយថ្មីគ្រប់គ្នាត្រេកត្រអាល
ប្រជាម៉ឺនពាន់រស់សមភក្ត្រា។

៥- ខេត្តកំពង់ស្ពឺល្បីខាងដើមត្នោត
វាលស្រែល្វឹងល្វើយប្រទាក់ក្រឡា
ច្បារមនក្រុងឆើតក្នុងដែនសីមា
ទីដែលប្រជារស់គាប់រៀងៗ។

៦- ឱ!ខេត្តកណ្ដាលជាថ្នាលជីវិត
មានខ្មែរ ចិន យួនរកស៊ីប្រិតប្រៀង
ក្រុងថ្មីល្អពិតតាខ្មៅអួតរាង
សោភ័ណស្ថិតស្ពានដក់ជាប់បេះដូង។

៧- រតនគិរីមណ្ឌលត្បូងពេជ្រ
ខ្សែបខាយសម្រស់សែនស្រស់ផូរផង់
ទិដ្ឋភាពរំលេចទីក្រុងបានលុង
ប្រជាសមទ្រង់ខុសពីអតីត។

៨- ឱ!ខេត្តស្ទឹងត្រែងតាក់តែងក្រុងថ្មី
គឺក្រុងស្ទឹងត្រែងតែងដក់ជាប់ចិត្ត
ខេមរាប្រុសស្រីរស់នៅជុំជិត
ពីមុនធ្លាប់គិតថានៅសែនឆ្ងាយ។

៩- តាកែវចំណាស់ច្បាស់ក្នុងសាវតារ
ក្រុងដូនកែវអើយចិត្តខ្ញុំមិនណាយ
កកើតខេមរាច្រើនសតវត្សប្លាយ
សាសន៍ច្រើនរបាយរស់នៅជួបជួន។

១០- មណ្ឌលគិរីទីសក្តិសម
ខេត្តខ័ណ្ឌឯនាយធ្លាប់ល្បីផ្ទួនៗ
ក្រុងសែនមនោរម្យកើតថ្មីសមសួន
ត្បូងថ្មកប់ពួនទឹកដីជនជាតិ។

១១- ខេត្តបាត់ដំបងវាលស្រែល្វឹងល្វើយ
ក្រុងបាត់ដំបងចិត្តប៉ងជួបទៀត
បានមកឃើញហើយមិនចង់ឃ្លៀងឃ្លាត
យប់យន់ផ្កាយព្រាតប្រហើរក្លិនស្រូវ។

១២- កោះកុងដែនដីមានដៃសមុទ្រ
ខេមរភូមិន្ទឃ្លាតកាយចិត្តនៅ
ក្រុងថ្មីមួយគត់បវរឆ្មើមឆ្មៅ
ស្រស់ស្រាយពេកក្រៃជំនោរជលសា។

១៣-ឱ!ខេត្តកំពតកំពូលដួងចិត្ត
រំលេចក្រុងថ្មីបង្កើនសក្តា
ទេសភាពល្អពិតដូចឋានសួគ៌ា
ក្រុងថ្មីនាមថាកំពតនេះឯង។

១៤- ឧត្តរមានជ័យសែនក្រៃសម្រស់
គឺក្រុងសំរោងកំណត់ជាក់ចែង
ក្រុងថ្មីមានឈ្មោះពិតឥតមានស្លែង
ធនធានក្រៃលែងប្រជាមានលាភ។

១៥- ខេត្តកំពង់ធំព្រំជាប់ទន្លេ
ក្រុងស្ទឹងសែនអើយប្រជាពិតជ្រាប
សំបូរម្លេះទេមច្ចាទឹកសាប
ក្រុងថ្មីមានភ័ព្វជីវភាពពិតល្អ។

១៦- ពោធិ៍សាត់លង់ស្នេហ៍ខំថែសម្ផស្ស ក្រុងថ្មីសែនស្រស់ប្រជាសាទរ
ពោធិសាត់ក្រុងថ្មីទឹកដីបវរ បុប្ផាស្ពានថ្មឈរអួតសោភ័ណ។
១៧- ឱ!ខេត្តសៀមរាបល្បីពេញទីបា ដំណែលក្សត្រាប្រាសាទរយពាន់
ទឹកដីអង្គរទេសចរគ្មេរគ្មាន់ ក្រុងថ្មីឮលាន់សៀមរាបប្រិមប្រិយ។
១៨- ខេត្តព្រះវិហារនាទិសឧត្តរ ថែចិត្តមិនល្អចង់លេបទឹកដី
បំផ្លើសប្រវត្តិទាំងច្បាស់ដូចថ្ងៃ ចាញ់បុណ្យបារមីក្រុងព្រះវិហារ។
១៩- ក្រចេះរៀងអាយមិនងាយនឹងជួប ផ្កាឈើល្អទ្រុបទាក់ទាញនេត្រា
ពិដោរឈ្មុយឈ្ងប់ខ្ជួបប្រាំងវស្សា ក្រុងថ្មីនេះណានាមថាក្រចេះ។
២០- ព្រៃវែងទិសបូព៌ជំនោរត្រសៀក ពេលបានមកកៀកពិតល្អអ្វីម្ល៉េះ
ព្រៃវែងក្រុងថ្មីសូមចាំឱ្យច្បាស់ រាស្ត្រទាំងក្មេងចាស់រស់ដោយអំណរ។
២១- ខេត្តព្រះសីហនុជាឋានឱសថ មានឆ្នេរសមុទ្រគាប់ចិត្តទេសចរ
ជំនោរត្រសៀករលកបោកថ្ម ក្រុងថ្មីសែនល្អឈ្មោះដូចខេត្តដែរ។
២២- ខេត្តកែបនាមខ្លីតែន័យសំខាន់ ប្រជាណែនណាន់គាប់ចិត្តម្ល៉េះទេ
ឆ្នេរខ្សាច់វាលរាបទេសចរហូរហែ ក្រុងកែបមានស្នេហ៍ខំថែសម្រស់។
២៣- ឱ!ខេត្តប៉ៃលិនមាសត្បូងពេជ្រក្រែក្រាស់ ប្រជារស់គាប់ត្បូងពេជ្រក្រែក្រាស់
ប៉ៃលិនក្រុងថ្មីសេដ្ឋកិច្ចលូតលាស់ ប្រុសស្រីក្មេងចាស់សន្តិរៀងអើយ៕

លោក **មាស សំភាស់**

គ្រូអនុវិទ្យាល័យហ៊ុនសែនសម្តេចពាន់ ខេត្តតាកែវ

ᯀ📖ᯀ

## បើដឹងមិនដល់កុំធ្វើចេះ

*បើដឹងមិនដល់កុំធ្វើចេះ ចំណេះតិចតួចស្ទួចស្តើងស្តឹង*
*បើចង់ច្បាស់លាស់ត្រូវខំប្រឹង កុំដេកសម្ងំឱ្យចេះឯង។*
*ចំណេះកើតមានដោយសាររៀន កម្ចិលអៀនប្រៀនកុំសម្តែង*
*ធ្វើឱ្យគេស្ញើចតេកោតក្រែង ស្វាក់ស្វែងទេកុំរិះគន់គេ។*
*ត្រូវរិះគន់ខ្លួនឯងជាមុន កុំឱ្យសិយស៊ុនខុសទទេ*
*បើឆ្ងល់ពុំយល់ត្រូវសួរគេ ឥតបោកអ្វីទេ ថ្លៃទេតើ។*
*បុរាណថាបោកអីនឹងដៃ ថ្លៃអីនឹងមាត់ពោលសើរើ*
*រៀនទៅសួរទៅទើបគ្រាន់បើ អើពើចង់ចេះប្រសើរណាស់។*
*ចាស់ថាបើល្ងង់កុំធ្វើចេះ មិនមានចំណេះឱ្យជាក់ច្បាស់*
*បើយើងហើយចង់ឱ្យបានក្រាស់ ត្រូវថែមកម្រាស់ផ្សំសាច់គ្នា៕*

**សម្តេចព្រះសង្ឃរាជ ជួន ណាត**

# ត្រូវចៀសវាងពីគ្រឿងញៀន

**(បទពាក្យប្រាំពីរ)**

១- ពួកយើងបានកើតមកជាមនុស្ស មានស្លាប់មានរស់ដូចៗគ្នា
ជាកូនខ្មែរមិនត្រូវពាលា ដូចគេផ្តន្ទាក្នុងជីវិត។

២- ពួកយើងត្រូវខំប្រឹងសិក្សា រាស្ត្រគ្រប់អាត្មាត្រូវចេះគិត
យើងកុំចង់ទៅតាមនៃបនិត្យ គ្រឿងញៀននេះពិតកាចសាហាវ។

៣- គ្រឿងញៀនពិតមានច្រើនប្រភេទ ត្រូវចេះសង្កេតកញ្ចាការ
ផឹកស៊ីជក់ម៉ាវាយគ្នាប្រាវ ដោះខោដោះអាវគ្មានអៀនខ្មាស។

៤- ដូច្នេះកូនខ្មែរអើយយើងត្រូវ កុំដើរចូលផ្លូវនាំអាម៉ាស់
ពួកយើងត្រូវចេះគោរពចាស់ គាត់ពិបាកណាស់ឱ្យក្មេងល្អ។

៥- ពួកយើងត្រូវជៀសវាងគ្រឿងញៀន កុំជក់អាភៀនទើបបវរ
យើងត្រូវធ្វើចិត្តឱ្យស្មោះសរ ទើបរូបយើងល្អគ្មានភិតភ័យ។

៦- បើប្រទេសយើងគ្មានថ្នាំញៀន គ្មានគេបៀតបៀនសែនមានន័យ
ប្រជាជនខ្មែរល្អប្រពៃ ត្រូវចេះលកលៃជាតិសាសនា។

៧- យើងជាកុមារត្រូវចេះខ្លាច វានាំឱ្យកាចដល់គ្រួសារ
ពួកយើងទាំងអស់ត្រូវរក្សា ទើបជាតិខេមរាល្អរុងរឿង។

៨- គ្រឿងញៀនចេះធ្វើឱ្យមនុស្សឆ្កួត ចេះធ្វើឱ្យអួត និងចិត្តសៀង
រូបកាយស្គមស្គាំងសាច់ឡើងលឿង ដើរបង្ករឿងនឹងអ្នកផង។

៩- អ្នកទាំងអស់គ្នាវាងឱ្យឆ្ងាយ គ្មានភាពអន្តរាយគ្មានរោគឆ្លង
ហាមទាំងអស់គ្នាដូចសព្វដង ត្រូវដើរកន្លងគេចឱ្យឆ្ងាយ។

១០- ឱ!កុលបុត្រកូនខ្មែរទាំងអស់ ពួកយើងបានផ្ដោះពិតដល់កាយ
ឥឡូវពួកយើងបានសប្បាយ គ្មានភាពខ្វល់ខ្វាយនៅក្នុងចិត្ត។

១១- ពុក និងម្ដាយសប្បាយនឹងកូន ប្រៀបដូចជាកូនរបូតពីធ្លាក់
សូមទាំងអស់គ្នាគិតឱ្យជាក់ ចៀសពីឧបសគ្គនាំស្នាក់ចង។

១២- សិស្សានុសិស្សទាំងឡាយអើយ អ្នកបានដឹងហើយនូវចំណង
គ្រឿងញៀននេះហើយគេមិនប៉ង ព្រោះថាចំណងចងខ្លួនយើង។

១៣- សូមអ្នកទាំងអស់ចាំឱ្យច្បាស់ យើងត្រូវហ៊ាសរត់ពីភ្លើង
អ្នកញៀនថ្នាំលួចទ្រព្យរលើង លួចទាំងស្បែកជើងយើងគ្រប់គ្នា។

១៤- គួរអាសូរដល់ប្រទេសជាតិ គិតគួររកស្នៀតខំការពារ
មកពីថ្នាំញៀនទើបពាលា ត្រូវគ្រប់អង្គាប្រុងប្រយ័ត្ន។

១៥- ពួកយើងត្រូវថែជាតិសង្គម កុំឱ្យរលំត្រូវកំចាត់
គ្រឿងញៀនទាំងឡាយឱ្យស្ងប់ស្ងាត់ ទើបទ្រព្យសម្បត្តិបានគង់វង្ស។

១៦- ដូចនេះកូនខ្មែរទាំងអស់គ្នា គ្រប់ពេលវេលាត្រូវផ្ចិតផ្ចង់
បើរៀនចេះហើយមិនងាយលង់ កលល្បិចគ្រប់ជ្រុងគ្មានទាស់ឡើយ។

១៧- នៅក្នុងប្រទេសកម្ពុជា មានភាពធូរធារល្អដល់ត្រើយ
ពួកយើងមិនត្រូវធ្វើកន្តើយ រូបយើងនេះហើយភាពថ្លៃថ្នូរ។

លោក **ឡុច ម៉ៅ** សាលាបឋមសិក្សាអន្លង់វិល



# ប្រវត្តិឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ

កញ្ជរជាស័ព្ទបាលី បានសេចក្ដីថា សត្វដំរី។

ដើមឡើយកញ្ជរនេះសម្បូរដោយសត្វដំរីស្រុក ហើយនៅក្នុងព្រៃមានសត្វដំរីព្រៃជាច្រើន។

ឯសត្វដំរីស្រុកគឺសត្វដែលព្រះរាជាចាត់ឱ្យចិញ្ចឹមសំរាប់ប្រើការខាងយុទ្ធសាស្ត្រ។

ក្នុងសតវត្សរ៍ទី១៧ កញ្ជរជាខេត្តមួយក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានរាជធានីនៅក្រុងឧត្តុង្គមានជ័យ។ នាម៉ឺនដែលនៅត្រួតត្រាក្នុងខេត្តនោះមានងារជា ព្រះស្រីនរេន្ទបវរគជសារ «កញ្ជរ»។

ក្នុងសតវត្សរ៍ទី១៧ មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់សោយព្រះទិវង្គតនៅត្រង់អូរជរខាងកើតកញ្ជរ សព្វថ្ងៃនេះ។ ព្រះមហាក្សត្រអង្គនេះព្រះនាមព្រះធម្មរាជា រាជសម្ភារ ព្រះពញាតូ សោយរាជសម្បត្តិពីគ.ស១៦២៩ ដល់ ១៦៣៤ ជាព្រះរាជបុត្រព្រះបាទជ័យជេដ្ឋាទី២ ប៉ែកខាងព្រះមាតាជាខ្មែរ។ សាវតារបស់ព្រះអង្គមានដូចតទៅ:

ព្រះម៉ែយួរបុប្ផាវតីជាគតុណង៉ាន់[១] នឹងព្រះរាជសម្ភារ ចៅពញាតូ ដែលព្រះបាទជ័យជេដ្ឋាទី២ ជាព្រះបរមរាជបិតាបានផ្សំផ្គុំតាំងពីព្រះរាជកុមារមក។ ក្រោយមកព្រះរាជសម្ភារចេញទៅទ្រង់ព្រះផ្នួស ព្រះបរមរាជបិតាទ្រង់ព្រះសុរគណ្ណគតទៅ។ សម្ដេចព្រះឧទ័យជាព្រះបិតុលាទទួលកាន់ការផែនដីជាជំនួស។ ព្រះឧទ័យក៏បង្ខំយកព្រះនាងបុប្ផាវតីធ្វើជាមហេសីកាលនោះព្រះនាងបុប្ផាវតីមិនទាន់គ្រប់ការផង ហើយក៏តែងតាំងព្រះនាងបុប្ផាវតីជាព្រះម៉ែយួរបុប្ផាវតីស្រីរតន៍។ ក្រោយមកព្រះពញាតូ បានលាចាកព្រះផ្នួស ហើយឡើងសោយរាជសម្បត្តិជាអម្ចាស់ផែនដី ទ្រង់ព្រះនាមថា ព្រះបាទសម្ដេចព្រះស្រីធម្មរាជាធិរាជរាមាធិបតី គង់នៅព្រះរាជវាំងកោះឃ្លោក សម្ដេចព្រះឧទ័យរាជា ជាព្រះបិតុលាដាក់ព្រះអង្គជាព្រះឧភយោរាជ គង់នៅរាជវាំងក្រុងឧត្តុង្គ។

ព្រះរាជសម្ភារមិនដាច់ព្រះរាជហឫទ័យនឹងព្រះនាងបុប្ផាវតីក៏ប្រកួតប្រកាន់មានះ សុភអក្សរ អក្ខរាទៅវិញទៅមកដោយបុព្វេនិវាសណាត់ពេលឱ្យព្រះនាងបុប្ផាវតីស្រីរតន៍ទៅជួបឯត្រើយពោធិព្រះបាទ ហើយនាំព្រះនាងបុប្ផាវតីទៅគង់នៅឯព្រះរាជវាំងកោះឃ្លោក។

សម្ដេចព្រះឧទ័យរាជាបានជ្រាបហើយ ត្រាស់បង្គាប់ឱ្យទាហានពរទុយហ្កេស៍លើកទ័ពទៅចាប់។ ពេលនោះខាងព្រះរាជសម្ភារវិញត្រាស់បង្គាប់ឱ្យទាហានខ្មែរ-ចិនចេញទទួលទ័ព តែទាហានខាងព្រះរាជសម្ភារខូចខាតជាច្រើន។ ព្រះរាជសម្ភារទ្រង់ឈ្វេងយល់ថា ជើងសឹកព្រះបិតុលាឧទ័យមានព្យុហខ្លាំងហួស ព្រះរាជសម្ភារក៏នាំព្រះអង្គម្ចាស់

(១)រាជសព្ទ: តួជណ្ដឹង

បុប្ផាវតីភៀសដោះព្រះអង្គចេញទៅដល់កន្លែងមួយត្រង់អូរជរ ជាទីមានព្រៃរបោះ មានដើមត្នោតច្រើននៅក្នុងឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះសព្វថ្ងៃនេះ។ ព្រះអង្គក៏ឡើងគង់លើដើមត្នោត។

ឯព្រះអង្គម្ចាស់បុប្ផាវតីទ្រង់ពួនក្នុងគម្ពោតព្រៃ។ ឯពួកអរិន្ទរាជកេរីពេលនោះ ដេញតាមប្រកិតប្រកៀកដៃ ព្រះរាជសម្ភារយល់ថាមិនរួចព្រះអង្គឡើយ ទ្រង់ចាប់ព្រះទំរង់ត្រឹមមុខកាត់ត្រួយត្នោត ហើយព្រះរាជនិពន្ធចារជាសេចក្ដីមិនទាន់ចប់សព្វគ្រប់ផង ស្រាប់តែកងទ័ពព្រះឧទ័យរាជាទៅដល់ឃើញព្រះអង្គប្រថាប់លើចុងត្នោត ក៏លើកកាំភ្លើងតម្រង់នឹងថ្វាយគ្រាប់មាសដល់ព្រះអង្គ តែព្រះអង្គតាំងព្រះរាជហឫទ័យដោយសេចក្ដីជាព្រះមហាក្សត្រទ្រង់រាជព្រះហស្ដ ហើយមានព្រះតម្រាស់ដោយព្រះសូរសៀងយ៉ាងខ្លាំងថា៖

បារាំងអប្បលក្ខណ៍ វាចោមបាញ់អ្នក ព្រះរាជសម្ភារ ពីលើចុងត្នោត មិនកោតចេស្ដា អ្នកយកហត្ថា រារាំងឃាំងឃាត់។

សេចក្ដីចារលើស្លឹកត្នោតដូចខាងក្រោមនេះ៖

សាធុសម្លាយ កុំបីរាយមាយ នឹងផ្លូវកាមា នាំឱ្យវង្វេង ក្នុងវដ្ដសង្សារ ស្លាប់ទៅកាលណា បានសោយតែទុក្ខ។

ព្រោះតែរូបស្រី នាំឱ្យអប្រិយ៍ ដូចត្រីក្នុងភក់ បើបុរសផង ចង់ឆ្លងនរក កុំឱ្យវិរក់ ដូចខ្ញុំច្នេះណា។

ពីព្រោះកាមេ ឥឡូវទាល់តែ ក្សិណក្ស័យជន្មា សូវស្លាប់ទៅគាប់ ឱ្យជាប់ធម្មា សូមអស់ទេវា ជួយជាទិព្វញ្ញាណ។ ទើបព្រះភូមិន្ទ នារាយធិបតិន្ទ្រ ទ្រង់ឧទ្ទិស្ថាន ពីនេះទៅមុខ ខ្ញុំសូមឱ្យបាន ជាព្រះពុទ្ធញាណ ស្រង់សត្វទាំងឡាយ។ ឱអ្នកទាំងពួង ជាទាហានហ្លួង នាំយកទៅថ្វាយ ព្រះបិតុលាបាន ជ្រាបអធិប្បាយ កុំឱ្យរាយមាយ នឹងផ្លូវកាមេ។

ព្រះរាជនិពន្ធចប់ហើយ ក៏ទម្លាក់ស្លឹកត្នោតដែលចារនោះមក ទាហានព័រទុយហ្គេស៍ ក៏ថ្វាយគ្រាប់មាសធ្លាក់ព្រះអង្គពីលើចុងត្នោត។

ឯព្រះអង្គម្ចាស់បុប្ផាវតី ទាហានព័រទុយហ្គេស៍ចាប់បាន ហើយធ្វើគត់ដោយទិឃាវុធក្នុងពេលនោះដែរ។ គេយកព្រះសពទាំងពីរព្រះអង្គទៅបូជា ហើយដង្ហែព្រះអដ្ឋិធាតុទៅតំកល់បញ្ចុះនៅវត្តព្រះវិហារធំសំបូរ ខេត្តក្រចេះក្នុងឆ្នាំ ១៦៣៤ លុះគ្រាបច្ចុប្បន្នកាលនេះ។

ដូច្នេះសម័យសតវត្សរ៍ទី១៧ កញ្ជរមានរឿងរ៉ាវជាសាវតារគួរកត់សម្គាល់បានថា ពិតជាខេត្តមួយមានឈ្មោះបោះសំឡេងក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលព្រះរាជសម្ភារព្រះអង្គបម្រុងទ័ពទប់ប្រឆាំងនឹងព្រះឧទ័យបាន។

គួរឱ្យអាណិតអាសូរអាណោចអាធ័មក្រៃលែងចំពោះព្រះអង្គដែលជាព្រះវីរក្សត្រខ្មែរមួយអង្គវាងវៃក្នុងការគ្រប់គ្រងរាជសម្បត្តិ ហើយមកសោយទិវង្គតនៅក្នុងព្រៃសមសាន្តស្ថានស្ងាត់ឆ្ងាយពីព្រះបរមរាជវាំងដូច្នេះ។

ដកស្រង់ដោយលោក **ខែម ផាន**
អធិការបឋមសិក្សា

---

«បណ្ឌិតរមែង ជាអ្នកស្គាល់កាល។»
**ពុទ្ធសុភាសិត**

# គោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ (ត)

**២.៣ សិទ្ធិ និងការទទួលខុសត្រូវរបស់ក្រសួង និងបុគ្គលិកក្នុងវិស័យអប់រំ**

១.ក្រសួងនឹងគោរពសិទ្ធិមន្ត្រីរបស់ខ្លួនក្នុងការចូលរួម និងផ្តល់ការពិគ្រោះយោបល់ពីការអនុវត្តគោលនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ។ ការចូលរួមគួរមានការសហការពីថ្នាក់ដឹកនាំ បុគ្គលិក និងតំណាងបុគ្គលិក។

២.រាល់ការសម្រេចចិត្ត និងសកម្មភាពទាំងអស់របស់ក្រសួងត្រូវមានការគោរពសិទ្ធិរបស់មន្ត្រី បុគ្គលិក និងសិស្ស និស្សិត (សូមមើលគោលការណ៍គន្លឹះ)។

**២.៤ ការបង្ការការឆ្លងមេរោគអេដស៍**

បរិយាកាសនៅតាមស្ថាប័នអប់រំគួរមានសុវត្ថិភាព ដើម្បីបង្ការការឆ្លងមេរោគអេដស៍ និងត្រូវមានការគាំទ្រអ្នកផ្ទុក ឬអ្នករងផលប៉ះពាល់ពីមេរោគអេដស៍ និងជំងឺអេដស៍។ គ្រប់ស្ថាប័នអប់រំទាំងអស់ក៏គួរតែលើកកម្ពស់ និងរក្សាបរិយាកាសសង្គមឱ្យបានល្អ។ បរិយាកាសដែលមានសុខភាព សុខុមាលភាព អហិង្សា និងសុវត្ថិភាពជាផ្នែកមួយដ៏សំខាន់សម្រាប់ការងារ និងការសិក្សាប្រចាំថ្ងៃ។

ដោយទទួលស្គាល់ថា ក្រសួងមានតួនាទីចំបងក្នុងការទប់ស្កាត់ការរាលដាលនៃមេរោគអេដស៍តាមរយៈទំនួលខុសត្រូវក្នុងការអប់រំ យុវជន និងកីឡា ដូចនេះក្រសួងនឹងមានវិធានការដូចខាងក្រោម៖

<u>សម្រាប់បុគ្គលិកសិក្សា</u>

ក្នុងម៉ោងធ្វើការ បុគ្គលិកសិក្សាទាំងអស់នឹងមានឱកាសចូលរួមក្នុងកម្មវិធីអប់រំស្តីពីមេរោគអេដស៍ ដែលរៀបចំដើម្បីបង្ហាញពីការព្រួយបារម្ភរបស់ខ្លួន ពាក់ព័ន្ធនឹងយុទ្ធសាស្ត្រដោះស្រាយបញ្ហាគ្រោះថ្នាក់ ក៏ដូចជាការថែទាំ ការព្យាបាល និងការគាំទ្រ។

កម្មវិធីនេះនឹង៖

- ផ្តល់ព័ត៌មានពិត និងថ្មីៗស្តីពីការឆ្លង រួមទាំងការបង្ការមេរោគអេដស៍
- ជួយឱ្យបុគ្គលិកដឹងពីគ្រោះថ្នាក់ និងយល់ពីវិធីបង្ការ និងការប្រុងប្រយ័ត្នជាសាកល
- ផ្តល់ការណែនាំស្តីពីការផ្លាស់ប្តូរឥរិយាបថ
- ជួយបុគ្គលិកក្នុងការរក្សាសកម្មភាព គ្មានការរើសអើង និងការមាក់ងាយចំពោះសិស្ស និស្សិត មាតាបិតា និងមានទំនាក់ទំនងល្អក្នុងសហគមន៍
- ប្រាប់បុគ្គលិកពីសិទ្ធិ និងផលប្រយោជន៍នៃការថែទាំ ការព្យាបាល និងមានគាំទ្រទាំងក្នុងស្ថាប័ន ទាំងក្នុងបរិយាកាសសហគមន៍មូលដ្ឋាន
- បញ្ចូលវិធីសម្រាប់តាមដានត្រួតពិនិត្យ វាយតម្លៃ និងការប្រជុំបូកសរុបប្រចាំឆ្នាំ។

<u>សម្រាប់សិស្ស និស្សិត</u>

សិស្ស និស្សិតក្នុងស្ថាប័នអប់រំទាំងអស់ គួរទទួលបាននូវកម្មវិធីអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍។ ការអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ គួរដាក់បញ្ចូលក្នុងកម្មវិធីសិក្សា និងក្នុងសកម្មភាពកម្មវិធីសិក្សាផងដែរ។ គោលដៅនៃការអប់រំស្តីពីមេរោគអេដស៍គឺធ្វើឱ្យការរស់នៅមានផាសុកភាព ផ្តល់បរិយាកាសប្រកបដោយការគាំទ្រ និង

ការថែទាំដល់អ្នកដែលរងផលប៉ះពាល់ពីមេរោគអេដស៍ និងជំងឺអេដស៍ និងកាត់បន្ថយឥរិយាបថដែលធ្វើឱ្យសិស្ស និស្សិតប្រឈមនឹងគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍។

កម្មវិធីអប់រំសម្រាប់សិស្ស និស្សិតនឹង:

- មានលក្ខណៈសមស្របចំពោះកម្រិតនៃការរីកលូតលាស់របស់សិស្ស និស្សិត
- ឆ្លើយតបទៅនឹងយេនឌ័រ
- បង្កើនចំណេះដឹង និងជំនាញដែលមានពីមុនមក
- ប្រើប្រាស់វិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព មានការចូលរួម និងមានលក្ខណៈសមស្របចំពោះវប្បធម៌
- លើកកម្ពស់ការយល់ដឹងពីជីវសាស្ត្រមនុស្សជាមូលដ្ឋាន (សុខភាពបន្តពូជ កាមរោគ គ្រោះថ្នាក់ នៃការប្រើថ្នាំញៀន) និងការព្យាបាល
- បង្កើតឱ្យមានឥរិយាបថប្រកបដោយការគាំទ្រដល់អ្នកដែលឆ្លង ឬអ្នកដែលរងផលប៉ះពាល់ពីមេរោគអេដស៍ និងជំងឺអេដស៍ និងប្រឆាំងនឹងការមាក់ងាយ និងការរើសអើងផ្សេងៗ
- បញ្ជាក់អំពីអត្ថប្រយោជន៍ក្នុងការតមការរួមភេទ ការរួមភេទដោយសុវត្ថិភាព ការប្រើប្រាស់ស្រោមអនាម័យ ភាពស្មោះត្រង់ចំពោះដៃគូតែម្នាក់ និងការចៀសវាងការប្រើថ្នាំញៀន និងជាតិស្រវឹង
- បង្ហាញការព្រួយបារម្ភរបស់សិស្សផ្ទាល់
- បញ្ចូលមធ្យោបាយសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ
- បង្រៀនដោយគ្រូដែលបានទទួលការបណ្តុះបណ្តាលយ៉ាងល្អ
- សមស្របចំពោះបរិយាកាសចិត្តសាស្ត្រសង្គម ស្របតាមបរិយាកាសរស់នៅរបស់អ្នកសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា នឹង:

១-បញ្ចូលកម្មវិធីលើកកម្ពស់ចំណេះដឹង និងការផ្សព្វផ្សាយខ្លីៗពីមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងការបណ្តុះបណ្តាល និងព្រឹត្តិការណ៍ផ្សេងៗដែលរៀបចំឡើងដោយមន្ត្រីក្រសួង។

២-ធានាឱ្យមានប្រអប់សង្គ្រោះបឋម និងសម្ភារៈបង្ការការឆ្លងសំខាន់ (ដូចជាស្រោមដៃប្លាស្ទិចដែលស្អិតជាប់ល្អ) សម្រាប់ប្រើប្រាស់ក្នុងស្ថានភាពបន្ទាន់ និងការប្រើជាប្រចាំ ដើម្បីបង្ការការឆ្លងមេរោគអេដស៍នៅតាមស្ថាប័នអប់រំគ្រប់ពេលទាំងអស់ ស្របតាមស្តង់ដាសកល។ កន្លែងធ្វើការនីមួយៗយ៉ាងហោចណាស់មានបុគ្គលិកពីរនាក់ ជាពិសេសគ្រូអប់រំកាយ និងគ្រូអប់រំបច្ចេកទេស/បណ្តុះបណ្តាលវិជ្ជាជីវៈដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីការសង្គ្រោះបន្ទាន់ និងវិធីការពាររបួសស្នាម។

**២.៥ ការអប់រំក្រៅប្រព័ន្ធ និងបុគ្គលិកផ្នែកកីឡា**

ដោយទទួលស្គាល់ថា ក្រសួងជ្រើសរើស និងជួលបុគ្គលិកជាច្រើន ដើម្បីផ្តល់ការអប់រំដល់យុវជន ដែលមិនបានចូលរៀនសាលារដ្ឋ (ជាពិសេសនៅតាមជនបទដាច់ស្រយាល) ហើយ ក្រសួងក៏មានការទទួលខុសត្រូវផងដែរចំពោះសកម្មភាពកីឡារបស់យុវជនទាំងនោះ ក្រសួងត្រូវ៖

១.លើកទឹកចិត្ត និងសម្របសម្រួលដល់បុគ្គលិកអប់រំក្រៅប្រព័ន្ធឱ្យប្រើប្រាស់កម្មវិធីបំណិនជីវិតឱ្យបានត្រឹមត្រូវ (ដែលកម្មវិធីនេះមានបញ្ចូលការអប់រំពីមេរោគអេដស៍) សម្រាប់យុវជនក្រៅសាលារៀន។

២.សហការជាមួយអង្គការក្រៅរដ្ឋាភិបាលនានាដែលធ្វើការទាក់ទងនឹងយុវជនក្រៅសាលារៀន។ សហការជាមួយសហជីពបុគ្គលិក និងនិយោជក ដើម្បីជួយយុវជនក្រៅសាលារៀន ដែលអាចជាប្រភពដ៏សំខាន់ក្នុងកម្លាំងការងារ។ (នៅមានត)

លោក **ប៉ិន តុលា**



# តើលោកគ្រូ អ្នកគ្រូដឹងឬទេ?

- **ប្រលោមលោក មុនដំបូងគេបំផុត ក្នុងប្រវត្តិអក្សរសិល្ប៍ខ្មែរ** គឺរឿង «ទឹកទន្លេសាប» និពន្ធដោយលោក គឹម ហាក់ ឬឆេង ហាក់។ ប្រលោមលោកដំបូងគេនេះ បានបោះពុម្ពនៅឆ្នាំ១៩៤១ ដោយព្រះរាជបណ្ណាល័យ។ តែនៅពេលបោះពុម្ពឡើងវិញ បណ្ណាគារអង្គរធំបានអះអាងថា «និពន្ធដោយលោក គឹម ហាក់ ឆ្នាំ១៩៣៩។ តែទោះជាបោះពុម្ពនៅឆ្នាំ១៩៣៩ ឬ១៩៤១ ក្តី ក៏រឿង «ទឹកទន្លេសាប» នេះ នៅតែជាប្រលោមលោកមុនដំបូងបង្អស់របស់ខ្មែរយើងដដែល។ លោក គឹម ហាក់ កើតនៅថ្ងៃទី៦ មករា ១៩០៥ (១៩១០?) នៅភ្នំពេញ ឪពុកឈ្មោះ អ៊ុក ឆេង ម្តាយឈ្មោះ កែវ ប៉ុច។ លោក គឹម ហាក់ ជាមន្ត្រីរាជការដ៏មានជោគជ័យម្នាក់ ហើយជាអ្នកដែលតែងតែជួយលើកតម្កើងព្រះពុទ្ធសាសនា និងជាអ្នកនិពន្ធផងដែរ។

- **កាសែតភាសាខ្មែរមុនដំបូងគេបំផុត ក្នុងប្រវត្តិសាស្ត្រខ្មែរ** មានឈ្មោះថា «នគរវត្ត» (Nagara Vatta)* ដែលបានបង្កើតឡើងនៅឆ្នាំ១៩៣៦ ដោយលោក ប៉ាច ឈឺន និងលោក ស៊ឺន ង៉ុកថាញ់ (ចេញផ្សាយលេខដំបូងនៅថ្ងៃទី ១៩ ធ្នូ ១៩៣៦)។

លោក ប៉ាច ឈឺន ជាចាងហ្វាងកាសែតនេះ។ ក្រៅពីលោក ស៊ឺន ង៉ុកថាញ់ នៅមានអ្នកប្រាជ្ញមួយចំនួនដែលមានគំនិតស្នេហាជាតិ តែពួកលោកជាមន្ត្រីរាជការ ពុំមានសិទ្ធិធ្វើនយោបាយបាន ជួយសរសេរអត្ថបទដោយលួចលាក់ ដូចជាលោក ស៊ឹម វ៉ា, ពិទូរ ឈឹម ក្រសេម, ញ៉ុក ថែម និងជុំ មួង ជាដើម។ ចំណែកព្រះសង្ឃដែលមានចំណេះដឹងជ្រៅជ្រះ និងមានទំនោរជាតិនិយមនាសម័យនោះ និងជាព្រះសង្ឃល្បីល្បាញក្នុងប្រវត្តិសាស្ត្រខ្មែរ ដូចជាអាចារ្យ ប៉ាង ខាត់ អាចារ្យ ខៀវ ជុំ អាចារ្យ ហែម ចៀវ ជាដើម សុទ្ធតែជាមនុស្សស្និទ្ធ នឹងកាសែតនគរវត្តនេះ។

*មានតម្កល់ទុកនៅបណ្ណាសារជាតិដល់សព្វថ្ងៃ

### ចំនួនឃុំ/សង្កាត់ មិនមានសាលាមធ្យមសិក្សា តាមខេត្ត-រាជធានី

2007-2010

| រាជធានី-ខេត្ត | 2007-2008 | 2008-2009 | 2009-2010 | 2010-2011 |
|---|---|---|---|---|
| បន្ទាយមានជ័យ | 0 | 0 | 0 | 0 |
| បាត់ដំបង | 13 | 9 | 5 | 4 |
| កំពង់ចាម | 59 | 30 | 14 | 6 |
| កំពង់ឆ្នាំង | 17 | 7 | 3 | 3 |
| កំពង់ស្ពឺ | 19 | 18 | 10 | 9 |
| កំពង់ធំ | 6 | 2 | 2 | 1 |
| កំពត | 18 | 3 | 2 | 2 |
| កណ្ដាល | 23 | 12 | 10 | 7 |
| កែប | 1 | 1 | 0 | 0 |
| កោះកុង | 9 | 9 | 9 | 8 |
| ក្រចេះ | 3 | 3 | 3 | 3 |
| មណ្ឌលគិរី | 13 | 13 | 11 | 11 |
| ឧត្ដរមានជ័យ | 6 | 5 | 4 | 4 |
| ប៉ៃលិន | 1 | 1 | 1 | 1 |
| ភ្នំពេញ | 39 | 37 | 37 | 39 |
| ព្រះវិហារ | 20 | 14 | 13 | 11 |
| ព្រៃវែង | 15 | 4 | 4 | 4 |
| ពោធិ៍សាត់ | 15 | 8 | 7 | 7 |
| រតនគិរី | 41 | 40 | 38 | 37 |
| សៀមរាប | 47 | 31 | 18 | 10 |
| ព្រះសីហនុ | 3 | 4 | 4 | 4 |
| ស្ទឹងត្រែង | 21 | 21 | 16 | 11 |
| ស្វាយរៀង | 18 | 17 | 8 | 8 |
| តាកែវ | 10 | 5 | 3 | 5 |
| **ទូទាំងប្រទេស** | 417 | 294 | 222 | 195 |

### ចំនួនឃុំ/សង្កាត់ មានសាលាមធ្យមសិក្សា តាមខេត្ត-រាជធានី

2010-2011

| រាជធានី-ខេត្ត | ចំនួនស្រុក | ចំនួនឃុំសរុប | ចំនួនឃុំមានសាលារៀន | | | |
|---|---|---|---|---|---|---|
| | | | តែអនុវិទ្យាល័យ | តែវិទ្យាល័យ | ទាំងអនុវិទ្យាល័យ និងវិទ្យាល័យ | មធ្យមសិក្សា |
| បន្ទាយមានជ័យ | 9 | 64 | 42 | 14 | 8 | 64 |
| បាត់ដំបង | 14 | 96 | 70 | 15 | 7 | 92 |
| កំពង់ចាម | 17 | 173 | 112 | 43 | 12 | 167 |
| កំពង់ឆ្នាំង | 8 | 69 | 53 | 10 | 3 | 66 |
| កំពង់ស្ពឺ | 8 | 87 | 58 | 16 | 4 | 78 |
| កំពង់ធំ | 8 | 81 | 60 | 15 | 5 | 80 |
| កំពត | 8 | 92 | 71 | 14 | 5 | 90 |
| កណ្ដាល | 11 | 127 | 92 | 25 | 3 | 120 |
| កែប | 2 | 5 | 3 | 1 | 1 | 5 |
| កោះកុង | 7 | 29 | 16 | 2 | 3 | 21 |
| ក្រចេះ | 6 | 46 | 33 | 5 | 5 | 43 |
| មណ្ឌលគិរី | 5 | 21 | 7 | 2 | 1 | 10 |
| ឧត្ដរមានជ័យ | 5 | 24 | 15 | 3 | 2 | 20 |
| ប៉ៃលិន | 2 | 8 | 5 | 2 | 0 | 7 |
| ភ្នំពេញ | 8 | 96 | 28 | 23 | 6 | 57 |
| ព្រះវិហារ | 8 | 49 | 30 | 2 | 6 | 38 |
| ព្រៃវែង | 13 | 116 | 90 | 20 | 2 | 112 |
| ពោធិ៍សាត់ | 8 | 49 | 29 | 7 | 6 | 42 |
| រតនគិរី | 9 | 49 | 10 | 0 | 2 | 12 |
| សៀមរាប | 12 | 100 | 72 | 16 | 2 | 90 |
| ព្រះសីហនុ | 4 | 26 | 15 | 5 | 2 | 22 |
| ស្ទឹងត្រែង | 5 | 34 | 17 | 2 | 4 | 23 |
| ស្វាយរៀង | 8 | 80 | 54 | 18 | 0 | 72 |
| តាកែវ | 10 | 100 | 53 | 34 | 8 | 95 |
| **ទូទាំងប្រទេស** | 193 | 1621 | 1035 | 294 | 97 | 1426 |

ដើមឈើដែលគេកាត់មែក វានឹងលាស់មែកថ្មី
ព្រះចន្ទដែលមានតែមួយចំណិត ថ្ងៃក្រោយក៏នឹងពេញបូណ៌មីឡើងវិញ

ឱម្នាលអ្នកជាំងឡាយអើយ អ្នកគួរសម្រេចសតិបញ្ញា ដោះរំលោះទុក្ខ
កុំឱ្យវាមកញាំញីលើយើងចាងឱ្យសោះ៕

**សុភាសិតសំស្ក្រឹត**

សមាគមបុគ្គលិកសិក្សាខ្មែរ

គណៈកម្មាធិការកណ្ដាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថិតសមាជិក តាមរាជធានី-ខេត្ត និងគណៈកម្មាធិការកណ្ដាល ប្រចាំឆ្នាំ២០១២

| ល.រ | ឈ្មោះខេត្ត | ចំនួនសមាជិកសរុប | | ចំនួនសមាជិកនៅបំរើការងារ | | ចំនួនសមាជិកចូលនិវត្តន៍ | |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | កំពង់ចាម | 12766 | 5,159 | 10499 | 4,829 | 2267 | 330 |
| 2 | ភ្នំពេញ | 12020 | 6,387 | 10716 | 5,864 | 1304 | 523 |
| 3 | កណ្ដាល | 9935 | 4,165 | 8441 | 3,822 | 1494 | 343 |
| 4 | បាត់ដំបង | 9212 | 4,023 | 8000 | 3,812 | 1212 | 211 |
| 5 | ព្រៃវែង | 8534 | 2,581 | 6905 | 2,442 | 1629 | 139 |
| 6 | តាកែវ | 8057 | 2,066 | 6789 | 1,949 | 1268 | 117 |
| 7 | កំពត | 6063 | 2,272 | 5226 | 2,151 | 837 | 121 |
| 8 | កំពង់ធំ | 5692 | 2,350 | 4813 | 2,138 | 879 | 212 |
| 9 | បន្ទាយមានជ័យ | 5815 | 2,129 | 5253 | 2,067 | 562 | 62 |
| 10 | សៀមរាប | 5657 | 2,797 | 4901 | 2,640 | 756 | 157 |
| 11 | ពោធិ៍សាត់ | 3978 | 1,382 | 3530 | 1,309 | 448 | 73 |
| 12 | ស្វាយរៀង | 4368 | 1,047 | 3535 | 976 | 833 | 71 |
| 13 | កំពង់ស្ពឺ | 4294 | 917 | 3770 | 805 | 524 | 112 |
| 14 | កំពង់ឆ្នាំង | 3755 | 1,293 | 3331 | 1,152 | 424 | 141 |
| 15 | ក្រចេះ | 2872 | 1,270 | 2341 | 1,175 | 531 | 95 |
| 16 | ព្រះសីហនុ | 1899 | 726 | 1705 | 699 | 194 | 27 |
| 17 | ព្រះវិហារ | 1187 | 335 | 1125 | 326 | 62 | 9 |
| 18 | ឧត្ដរមានជ័យ | 780 | 86 | 633 | 83 | 147 | 3 |
| 19 | ស្ទឹងត្រែង | 649 | 224 | 551 | 216 | 98 | 8 |
| 20 | ប៉ៃលិន | 660 | 244 | 650 | 230 | 10 | 14 |
| 21 | កោះកុង | 625 | 191 | 528 | 186 | 97 | 5 |
| 22 | រតនគិរី | 500 | 132 | 457 | 131 | 43 | 1 |
| 23 | កែប | 366 | 131 | 300 | 124 | 66 | 7 |
| 24 | មណ្ឌលគិរី | 381 | 146 | 366 | 141 | 15 | 5 |
| 25 | ថ្នាក់កណ្ដាល | 3286 | 977 | 2570 | 721 | 680 | 256 |
| **សរុប** | | 113,351 | 43,030 | 96,935 | 39,988 | 16,380 | 3,042 |

**សំគាល់:**

1. តួលេខសរុបជាចំនួនសមាជិកត្រូវបង់ថវិកាចូលមកបេឡាសមាគមប្រចាំខែធ្នូ ២០១២
2. តួលេខស្ត្រីជាតួលេខរបាយការណ៍ពាក់កណ្ដាលអាណត្តិទី១១ ឆ្នាំ ២០១២
3. តួលេខស្ត្រីខេត្តព្រះវិហារជាតួលេខរបាយការណ៍ ឆ្នាំ ២០១១
4. តួលេខខេត្តរតនគិរីជាតួលេខរបាយការណ៍ ឆ្នាំ ២០១១

ដកស្រង់ដោយ **គុយ ផល្លា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ : ៣៦/១២ គ.ក

**សេចក្តីជូនដំណឹងមរណភាពប្រចាំខែ កញ្ញា ឆ្នាំ២០១២**

ពាក់នាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមរំលែកទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | ប្រភេទបុគ្គល | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខបណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណៈភាពសមាជិក | | | | សមាជិក |
| ១ | អ៊ុំ សុខហ៊ាង | ៦៥ | ប | គ្រូ. | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល ស.ប.ស.ខ. | ១៤.០៧.១២ | រោគាពាធ | ១៣១៣ ត.ក | ៨៤២៨ |
| ២ | យិន វណ្ណា | ៥៩ | ស | គ្រូ. | ស.រ. ភូមិន្ទនីតិសាស្ត្រ /.សេដ្ឋកិច្ច ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល ស.ប.ស.ខ. | ១៧.០៧.១២ | រោគាពាធ | ១៩១៧ ត.ក | ៨៤២៩ |
| ៣ | ប៊ុត ប៊ុនធឿន | ៤៣ | ប | កីឡា. | នា. អប់រំកាយ និងកីឡា ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល ស.ប.ស.ខ. | ០៤.០៨.១២ | រោគាពាធ | ២៥២៩ ត.ក | ៨៤៣០ |
| ៤ | ហុក សំបូរ | ៧០ | ប | គ្រូ. | និវត្តជន បឋមក្រពៅ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ | ៣១.០៨.១២ | ជំងឺរបេង | ១៨០២ ប.ជ | ៨៤៣១ |
| ៥ | សោម នាត | ៥៤ | ប | បឋម | បឋមត្របែក ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ | ០១.០៨.១២ | ដាច់សរសៃឈាមខួរក្បាល | ២៨៥ ប.ជ | ៨៤៣២ |
| ៦ | អេម ឡញ | ៥០ | ប | បឋម | បឋមសិក្សាស្រះថ្មែង ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ | ២២.០៨.១២ | រលាកថ្លើម និងប្រមាត់ | ២៦០៧ ប.ជ | ៨៤៣៣ |
| ៧ | អ៊ុង ណាក់ | ៤៥ | ប | បឋម | បឋមទំនប់ដាច់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ | ០៤.០៨.១២ | រោគាពាធ | ៥១៨៦ ប.ម | ៨៤៣៤ |
| ៨ | មាស សាម៉ន | ៦៦ | ប | គ្រូ. | និវត្តជន បឋមព្រៃបន្ទំ ស្រុកបន្ទាយមាស ខេត្តកំពត | ២៨.០៦.១២ | រោគាពាធ | ៣០៩៩ ក.ព | ៨៤៣៥ |
| ៩ | យៀវ សឿន | ៧៦ | ប | គ្រូ. | និវត្តជន បឋមត្រពាំងសាលា ស្រុកបន្ទាយមាស ខេត្តកំពត | ១៧.០៧.១២ | រោគាពាធ | ៣៨៨៩ ក.ព | ៨៤៣៦ |
| ១០ | យុន ញ៉ាំ | ៥៨ | ប | បឋម | បឋមដំបូកខ្ពស់ ស្រុកអង្គរជ័យ ខេត្តកំពត | ២២.០៧.១២ | លើសឈាម | ១៨២៣ ក.ព | ៨៤៣៧ |
| ១១ | ណាំ ផាណាត | ៧០ | ស | គ្រូ. | និវត្តជន មនយាក ខេត្តកំពត | ២៤.០៧.១២ | រោគាពាធ | ៤២១០ ក.ព | ៨៤៣៨ |
| ១២ | រ៉ែត សុខ | ៥៦ | ប | បឋម | បឋមកោះរ៉ាំង ស្រុកបន្ទាយមាស ខេត្តកំពត | ០១.០៨.១២ | រោគាពាធ | ៣១៦៨ ក.ព | ៨៤៣៩ |
| ១៣ | រ៉ែត ឡឿង | ៧១ | ប | គ្រូ. | និវត្តជន បឋមឃ្លាយខាងត្បូង ស្រុកដងទង់ ខេត្តកំពត | ២៨.០៧.១២ | រោគាពាធ | ២៦៧៣ ក.ព | ៨៤៤០ |
| ១៤ | អ៊ុក សឿង | ៦៥ | ប | គ្រូ. | និវត្តជន វិទ្យាល័យ ហ.ស ឈូក ស្រុកឈូក ខេត្តកំពត | ១០.០៨.១២ | រោគាពាធ | ២១៥០ ក.ព | ៨៤៤១ |
| ១៥ | អំ គន | ៤៥ | ប | បឋម | បឋមក្រាំងស្វាយ ស្រុកឈូក ខេត្តកំពត | ២០.០៨.១២ | រន្ទះបាញ់ | ២៤២៧ ក.ព | ៨៤៤២ |
| ១៦ | សុខ សុខុម | ៦៣ | ប | ម.ប.ភ | និវត្តជន អនុ.អយក ស្រុកសង្កែ ខេត្តបាត់ដំបង | ០៣.០៧.១២ | រោគាពាធ | ៥៣៧៥ ប.ប | ៨៤៤៣ |
| ១៧ | ញ៉ុង ស៊ីនួន | ៥៧ | ប | បឋម | បឋមអន្លង់តាម៉ី ស្រុកបាណន់ ខេត្តបាត់ដំបង | ១៥.០៧.១២ | រោគាពាធ | ៣៣៣៩ ប.ប | ៨៤៤៤ |
| ១៨ | សរ យួម | ៥៩ | ប | បឋម | បឋមល្វា ស្រុកបវេល ខេត្តបាត់ដំបង | ១១.០៧.១២ | ជំងឺថ្លើម | ៣០៥២ ប.ប | ៨៤៤៥ |
| ១៩ | អ៊ិម ឈុន | ៧៩ | ប | បឋម | និវត្តជន បឋមដារ ស្រុកមេមត់ ខេត្តកំពង់ចាម | ២៧.០៦.១២ | រោគាពាធ | ៥៥៥ ក.ច | ៨៤៤៦ |
| ២០ | តូច សារ៉ាន | ៦៧ | ប | បឋម | និវត្តជន បឋមស្លាង ស្រុកជើងព្រៃ ខេត្តកំពង់ចាម | ២០.០៦.១២ | រោគាពាធ | ២៦១៣ ក.ច | ៨៤៤៧ |
| ២១ | ប៉ែន សា | ៦៦ | ប | បឋម | និវត្តជន អនុ.អយក ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | ១០.០៧.១២ | រោគាពាធ | ១៩៥៨ ក.ច | ៨៤៤៨ |
| ២២ | ឈន ឡាន | ៧០ | ប | បឋម | និវត្តជន បឋមតំបែរ ស្រុកតំបែរ ខេត្តកំពង់ចាម | ០៧.០៦.១២ | ជរាពាធ | ៦២០២ ក.ច | ៨៤៤៩ |
| ២៣ | រឿង រី | ៦០ | ប | បឋម | និវត្តជន បឋមឈ្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម | ២៦.០៦.១២ | រោគាពាធ | ៤៩៨០ ក.ច | ៨៤៥០ |
| ២៤ | ឃឹម ផាន់ | ៧៣ | ប | បឋម | និវត្តជន បឋមព្រៃកូនជ្រូក ស្រុកកោះសូទិន ខេត្តកំពង់ចាម | ២៥.០៦.១២ | រោគាពាធ | ៤៧៧៦ ក.ច | ៨៤៥១ |
| ២៥ | ស៊ូ ចាន់ថេត | ៥៦ | ប | បឋម | និវត្តជន បឋមចុងកោះត្បូង ស្រុកកោះសូទិន ខេត្តកំពង់ចាម | ២៩.០៦.១២ | លង់ទឹក | ៤៨៤៤ ក.ច | ៨៤៥២ |
| ២៦ | ម៉ក់ ម៉េ | ៧២ | ប | បឋម | និវត្តជន បឋមម្សៀន ស្រុកអូរាំងឪ ខេត្តកំពង់ចាម | ២៦.០៦.១២ | រោគាពាធ | ៩៨២ ក.ច | ៨៤៥៣ |
